# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សោម ម៉េត K05435

ជួបជាមួយលោកពូ សោម ម៉េត អាយុ៤៥ ភេទប្រុស ជាម្ចាស់ប្រវត្តិរូប
រស់នៅក្នុងភូមិកំពង់សំបួរលើ ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល
មុខងារសម័យខ្មែរក្រហមៈ កងការពារនៅមន្ទីរស-២១
ថ្ងៃ ១៣ ខែ កញ្ញា ឆ្នាំ២០០៤
សម្ភាសន៍ដោយៈ ស៊ីវ. ជានិងសុខឃាង
សរុបៈ ៤២ទំព័រ

**ស៊ីវៈ** ពូកាលពីឆ្នាំទៅខ្ញុំបានមកសួរមួយសារដែរពីរឿងរ៉ាវជីវិតពូ ដែលបានឆ្លងកាត់រយៈពេល ៣០ឆ្នាំមកនិងហើយរឿងរ៉ាវទាំងអស់និងខ្ញុំចាត់ទុកថាជារឿងរ៉ាវៈបវត្តិសាស្ត្រមួយ ទុកឲ្យក្មេងជំនាន់ក្រោយឿនសិក្សាបានលីដែរ ហើយខ្ញុំមកលើកទីពីរនេះដោយសារមូលហេតុដែលពីមុននិងការសួររបស់ខ្ញុំនិងដូចថាវ៉ានៅស្ទើរដែរ ហើយវ៉ាមានការខ្វះចន្លោះនៅសំនួរខ្វះហើយខ្ញុំមកលើកនេះមកបំពេញចន្លោះដែលខ្ញុំខ្វះខាត ដើម្បីយកទៅចងក្រងជាសៀវភៅជាឯកសារមួយសំរាប់ការស្រាវជ្រាវទៅថ្ងៃក្រោយទៀត។ ពូឈ្មោះសោម ម៉េត អត់មានឈ្មោះអីផ្សេងទៀតក្រៅពីនិងទេ អាយុប៉ុន្មានពល់ថ្ងៃហ្នឹង?

**ម៉េតៈ** អាយុឥឡូវ៤៦ហើយ។

**ស៊ីវៈ** ពូកើតជានៅឯណាដែរ?

**ម៉េតៈ** ស្រុកកំណើតនៅភូមិព្រែកនិងស្រុក ឃុំព្រែកក្តី ស្រុកកោះធំយើងនេះ។

**ស៊ីវៈ** ហើយមកនៅនេះតាំងពីឆ្នាំណាដែរ?

**ម៉េតៈ** ខ្ញុំមកនៅនេះតាំងពីឆ្នាំ៨០ តាំងពីខ្ញុំមកពីព្រៃវិញមាកាត់រកប្រពន្ធឲ្យក៏មកនៅនេះទៅ។

**ស៊ីវៈ** មកនៅខាងប្រពន្ធនេះមក អីចឹងនេះភូមិ?

**ម៉េតៈ** ភូមិកំពង់សំបួរលើ ឃុំព្រែកថ្មី ស្រុកកោះធំដដែល។

**ស៊ីវៈ** ហើយពូមកនៅនេះមានប្រពន្ធកូន តើឥឡូវនេះមានកូនប៉ុន្មានហើយ?

**ម៉េតៈ** មានកូន៥នាក់។

ស៊ីវៈ ប្រពន្ធឈ្មោះអីដែរ?

ម៉ើតៈ ប្រពន្ធឈ្មោះ ឈៀ ហ៊ុយណេង ។

ស៊ីវៈ ពូប្រកបមុខរបរធ្វើការងារអីដែរ?

ម៉ើតៈ សព្វថ្ងៃនេះខ្ញុំអត់មានអីលើសពីធ្វើស្រែចំការទេ ។

ស៊ីវៈ ពូឥឡូវយើងត្រឡប់ទៅកាលពីជំនាន់មុនវិញ កាលពូនៅពីក្មេងៗពូបានរៀនសូត្រអីដែរទេ រៀននៅតាមសាលារ?

ម៉ើតៈ ពីមុនខ្ញុំបានរៀនដែរ រៀននៅសាលាវត្ត នៅវត្តព្រែកស្តីធ្វើកូនសិស្សលោកផងរៀននៅនិងផង ដល់ឪពុកស្លាប់ទៅ គាត់ស្លាប់នៅឆ្នាំ៧២ហ្នឹង ហើយនៅធ្វើការធ្វើជាមួយម្តាយនិង រហូតដល់គេមកហៅខ្ញុំនិងយកទៅធ្វើ មុនដំបូងធ្វើឈ្លបឃុំតែម្តាយខ្ញុំគាត់ថាអត់ឲ្យទៅទេ គេមកតាមពីរបីដងអានេះដូចថាវាកៀងយើងឲ្យយើងទៅ ព្រោះតំណាក់កាលនិងវាជាតំណាក់កាលដែលប្រថុចញុច ។

យ៉ាងៈ កាលនិងពីណាគេជាអ្នកមកហៅឲ្យទៅ?

ម៉ើតៈ ឈ្មោះយិប ឥឡូវងាប់បាត់ហើយ ។

យ៉ាងៈ កាលហ្នឹងគាត់ប្រធានឃុំ?

ម៉ើតៈ ប្រធានភូមិ កៀងទៅនិងដល់ហើយខ្ញុំក៏ប្រកែកដែរ ថាខ្ញុំនៅជួយម្តាយសិនព្រោះអីឪពុកខ្ញុំគាត់ស្លាប់បាត់ហើយ អីចឹងខ្ញុំនៅជួយម្តាយដល់ហើយគេក៏មិនព្រម គេក៏បញ្ឆោតយើងឲ្យនៅត្រឹមឃុំអីចឹងទៅ ដល់ហើយគេចេះតែដេញយើងទៅភស្តុភារ ទៅដល់អន្ទង់តំបន់មួយជួរទន្លេមេគង្គនិងណា ។

យ៉ាងៈ ពេលទៅដល់ស្រុកពូធ្វើអីដែរ?

ម៉ើតៈ ធ្វើតែឈ្លបនាយអាយកាលហ្នង់យើងនៅតូចអាយុជាង១០ឆ្នាំ ។

យ៉ាងៈ ពីណាគេជាប្រធានស្រុកចៅហ្វាយស្រុក?

ម៉ើតៈ ហ៊ឺ!ខ្ញុំអត់ចាំទេ ភ្លេចហើយកាលនិងដឹងតែតាកាត ក្រៅពីតាកាតមិនដឹងពីណាទៀត ខ្ញុំក៏វាភ្លេចដែរកាលនិងដូចថាវានៅតូចៗ មានដឹងថាអ្នកណាធំអ្នកណាតូចអីនឹកឃើញតែគេហៅចេះតែទៅៗ ។

យ៉ាងៈ កាលនិងអាយុប៉ុន្មាន?

**ម៉ឺត:** កាលនិងអាយុជាង១០ឆ្នាំ មិនដឹងជា១០ប៉ុន្មានៗ

**យ៉ាង:** ១០ឆ្នាំជាងតិចតួច?

**ម៉ឺត:** បា!១៦អីអស់

**ស៊ីវ:** ចុះកាលនិងពូទៅតែម្នាក់ឯងឬក៏មានពីណាគេ?

**ម៉ឺត:** មានគ្នាពីរនាក់ៗ

**យ៉ាង:** ពីណាគេទៀត?

**ម៉ឺត:** ឈ្មោះអីតយអីមិនដឹងទេនៅហូយួនយើងពីដើម ធ្វើទ័ពនិងឆ្នាំ៧៣ៗ

**យ៉ាង:** ក្រោយពីនិងពូទៅដល់ភាគ?

**ម៉ឺត:** ភាគនិរតីយើង បុិនខាងទន្លេមេគង្គគេរៀបឲ្យធ្វើទ័ពធ្វើអីចូលគ្នា បុិនមុនដំបូងយើងមិនទាន់ធ្វើអីទេ យើងជាកុមាររែកបាយទេរែកបាយស្នុកយកទៅឲ្យទ័ពនៅខាងខ្សែភាគគេហ្នឹងៗ

**យ៉ាង:** មន្ទីរគេនៅឯណាដែរ?

**ម៉ឺត:** មន្ទីរគេនិងវាពិបាកដែរ វានៅគ្រប់កន្លែងទាំងអស់ចល័តទាំងអស់ ជួនកាលគេនៅស្រុកលើកដែកនេះឃុំលើកយើងនេះ ជួនកាលគេនៅស្អាងព្រែកតូចនេះទៅៗ

**ស៊ីវ:** ប៉ុន្តែមែនទែនទៅភូមិភាគនៅកន្លែងនិង ជាភូមិនិរតីឬក៏ភូមិភាគពិសេស នៅក្នុងជំនាន់សង្រ្គាម៥ឆ្នាំនិងណា?

**ម៉ឺត:** អា៥ឆ្នាំនិងនៅក្នុងសង្រ្គាមហ្នឹង វាជាភូមិភាគពិសេសហើយបុិនតែវានៅក្នុងនិរតីយើងទេ

**ស៊ីវ:** ប៉ុន្តែអ្នកដែលទទួលខុសត្រូវពេលនោះហើយ ដែលលោកពូចូលទៅក្នុងកងពលលេខ១២ និងហ្នឹ របស់តាណាតតាពីន?

**ម៉ឺត:** បា!បា!ៗ

**ស៊ីវ:** នៅក្នុងពេលសង្រ្គមនៅឡើយ នៅក្នុងពេលសង្រ្គាម៥ឆ្នាំ?

**ម៉ឺត:** ៥ឆ្នាំនិងខ្ញុំនៅក្នុងកងពល១២របស់ អ៊ិន ណាត តាពីនៗ

**ស៊ីវ:** ហើយតាណាតនិងគាត់ជាលេខារបស់កងពល ហើយតាពីននិងជាអនុរបស់គាត់?

**ម៉ឺត:** បាទ!បាទ!ៗ

**ស៊ីវ:** ហើយលោកពូនៅវរសេនាធំ២៧០?

**ម៉ឺត:** ២៧០អត់ទេ វរសេនាធំ២៧០ កងពល១២ៗ

ស៊ីវៈ ហើយវរសេនាតូចពេលនោះ?

ម៉ើតៈ វរសេនាតូចពេលនោះ គិតទៅលេខ២៧៥ អានិងគេបង្កើតពីស្រុកទៅ ។

ស៊ីវៈ អ៊ីចឹងកងពលជាទូទៅវាមាន៣វរសេនាធំ?

ម៉ើតៈ កងពលនិងខ្ញុំវាពិបាកភ្លេចដែរ មិនដឹងជាប៉ុន្មានវរសេនាធំទេដឹងតែខ្លួនឯងផ្ទាល់និងហ្នឹង ។

ស៊ីវៈ វរសេនាធំ២៧០និងហ្អេ?

ម៉ើតៈ បា!អានិងគេបង្កើតថ្មី ។

ស៊ីវៈ វរសេនាតូចនិងលេខ២៧៥ ហើយនៅអង្គភាពនិងរហូតដល់ថ្ងៃ១៧មេសា?

ម៉ើតៈ ខ្ញុំនៅអង្គភាពនិងរហូតដល់ថ្ងៃ១៧មេសាហ្នឹង ។

ស៊ីវៈ ខ្ញុំឃើញគេសម្ភាសន៍លោកពូកាលពីលើកមុននិងណា ពេលនោះហើយលោកពូនៅខាងនិរសាជាមួយតាឈុន ហើយតាឈុន និងគាត់ជាអ្នកវរសេនាតូច២៧៥និងហ៎្អ?

ម៉ើតៈ អត់ទេ វរសេនាធំ២៧០ ។

ស៊ីវៈ អ៊ីចឹងគាត់ជាលេខាវរសេនាធំនិងតែម្តង?

ម៉ើតៈ បាទ!

ស៊ីវ ៈ ហើយលោកពូសម្ភាសន៍លើកមុននិងលោកពូមានប្រសាសន៍ថា ចូលភ្នំពេញនិងខាងដែលចូលមុនគេមានកងកំលាំងពិសេសរបស់កងពលមិនអ៊ីចឹង?

ម៉ើតៈ បាទ!

ស៊ីវ ៈ កងពិសេសរបស់កងពលនិង កាលដែលចូលមកភ្នំពេញនិងអ្នកណាជាប្រធាន?

ម៉ើតៈ កាលហ្នឹងវាពិបាកដែរខ្ញុំភ្លេចក៏មិនបានដែរ ប៉ុនតែខ្ញុំមានតែពីនហើយនិងតាណាតនិងទេ គាត់ជាអ្នកចាត់ចែងនៅទីក្រុងហ្នឹង គាត់ជាអ្នកចាត់ចែងឲ្យកូនចៅទាហានទ័ពអីហ្នឹង នៅការដ្ឋានគ្រប់កន្លែងទាំងអស់ ។

ស៊ីវៈ ប៉ុន្តែអ្នកខ្លះបាននិយាយថាឈ្មោះហូរនិងណា ជាប្រធានកងកំលាំងពិសេសរបស់កងពលពិសេសនៅក្នុងពេលសង្គ្រាម?

ម៉ើតៈ ឈ្មោះហូរ ។ ហូរដែកខ្វាក់ភ្នែកនោមន្ទីរស-២១និងហ៎្អ បាទនិងគាត់ជាអ្នកកងពិសេស ១៨៣ កងពិសេស១៨៣អានិងកងពិសេសហ្នឹង ។

ស៊ីវៈ ១៨៣និងជា..?

**ម៉ើត៖** ១៨៣និងជាកងពិសេសរបស់កងពល ។

**ស៊ីវ៖** ជាចំណុះរបស់កងពលតែម្តង ឬក៏ចំណុះកងពលណាផ្សេងទៀត?

**ម៉ើត៖** ចំណុះកងពលតែម្តង កងពិសេសរបស់គេ ។

**ស៊ីវ៖** អានិងវរសេនាតូច?

**ម៉ើត៖** បាទ! វរសេនាតូច១៨៣ហ្នឹង ។

**ស៊ីវ៖** ហើយយើងដឹងថាក្នុងពេលដែលចូលភ្នំពេញថ្ងៃ១៧មេសាហ្នឹង កងពិសេសដែលចូលមុនគេនិងមានទទួលបញ្ជាយ៉ាងម៉េច ដោយកម្មេចបណ្តាលសក្តិនាយទាហានលន់ នល់ហ្នឹង ឬក៏រដ្ឋការលន់ នល់អីមានទេ?

**ម៉ើត៖** កាលនិងដែលខ្ញុំចូលទៅហ្នឹង ចុះធម្មតាដែលខ្ញុំនិរសាហ្នឹងចេះតែដើរតាមក្រោយគេទៅណា ហើយពួកគេទៅមុនអស់ហើយ ហើយពួកខ្ញុំនៅតាមក្រោយនិងចេះតែទៅៗ ហើយប្រជាជននិងចេះតែចុះមករហង់ តាមគ្រប់ទិសទីទាំងអស់មករហូត ព្រោះអីខ្ញុំមកតាផ្លូវព្រែកតូចយើងនេះណា ទៅអីចឹងទៅផ្ទល់ជាតិតាមមាត់ទន្លេយើង ចេះឃើញប្រជាជនមក ប៉ុនមិនដឹងថាភូមិភាគណាគេដល់ត្រឹមណាមុនៗអីទេ ប៉ុន្តែខ្ញុំមកដល់ត្រឹមតែតាខ្មៅទេ អត់បានចូលទីក្រុងទេ ចូលបានត្រឹមតែតាខ្មៅទេ ។

**ស៊ីវ៖** ហើយបញ្ហាយ៉ាងណាដែលនៅក្នុងកងពល១២ហ្នឹង ទទួលបញ្ជារ អនុវត្តន៍បញ្ជារឲ្យដើរបោសសំអាតទាហាន ដែលសេះសល់របស់លន់ណុល មិនដឹងជាអង្គភាពខាងណាជាអ្នកទទួលជាអ្នកអនុវត្តន៍ទេ?

**ម៉ើត៖** កាលនិងខ្ញុំក៏អត់បានដឹងដែរ អត់បានដឹងរឿងថាមួយណាជាមេបញ្ជារហ្នឹង បើគិតទៅវាមានតែដូចជាមេពីមុនមកមានតែ ប៉ុល ពត តាម៉ុកអីចឹងទៅគេជមេហើយអាហ្នឹង ។

**ស៊ីវ៖** ប៉ន្តែនៅក្នុងអង្គភាពខ្លួនឯង?

**ម៉ើត៖** នៅក្នុងអង្គភាពខ្លួនឯងនិងវាមានតែដូចជា តាណាត, តាពីន, តាឈុនអីនិងគាត់វរសេនាធំ គាត់ចេះតែសហការណ៍ជាមួយកងពលហើយណា អានិងវាមានតែអីចឹងទេ ។

**ស៊ីវ៖** អីចឹងវរសេនាធំរបស់ខ្លួនឯងនិង២៧០ហ្នឹង តាឈុននិងគាត់ជាមេ?

**ម៉ើត៖** គាត់ជាមេស្នងការ ។

**ស៊ីវ៖** ហើយឪ និងគាត់នៅខាងណាដែរ?

**ម៉ឺត:** ឪ និងខាងកំលាំងជាមួយគ្នា ។

**ស៊ីវ:** អនុរបស់ឈុនហ្នឹង?

**ម៉ឺត:** បាទ! ។

**ស៊ីវ:** ហើយវរសេនាធំផ្សេងៗនិងអត់ដឹងទេ?

**ម៉ឺត:** វរសេនាធំផ្សេងៗអត់ដឹងទេ ។

**ស៊ីវ:** ដឹងតែរបស់ខ្លួនឯង?

**ម៉ឺត:** បា!ដឹងតែរបស់ខ្លួនឯង ។

**ស៊ីវ:** ប៉ុន្តែអារឿងខាងកងពលនិងបានទទួលបញ្ជារថា ឲ្យបោសសំអាតនាយទាហានលន់ នល់ ដែលនៅទីក្រុងនិងមានបានលឺដែរ ឬក៏អត់ទេ?

**ម៉ឺត:** បានលឺ លឺគេប្រកាសថាឥឡូវយើងមកដល់ទីក្រុងភ្នំពេញហើយ យើងត្រូវតែបោសសំអាតទីក្រុងដើម្បីឲ្យវាលទីក្រុងហ្នឹង ដើម្បីងាយស្រួលនិងគេធ្វើការ ទី១គេខ្លាចថានៅមានសម្ងាត់ដូចគីញអីនិងដែលគេបង្កប់ខ្លួនហ្នឹង អានិងត្រូវគេបោសសំអាត ប៉ុនខ្ញុំគ្រាន់តែបានលឺសូរទេណា ប៉ុនរយៈនិងខ្ញុំត្រូវគេដកមកឲ្យរៀននៅសាលាបច្ចេកទេសនៅគាខ្មៅនេះទេ

**ស៊ីវ:** លឺសូរនិងលឺពីអ្នកណាមក?

**ម៉ឺត:** លឺហ្នឹង ដូចលឺពីឈុន វរសេនាតូចដែលនៅក្នុងវរសេនាធំដែលនៅក្នុងនិងអីហ្នឹងណា គេច្រើនតែប្រជុំទៅគេច្រើនតែនិយាយថាខទាហរណ៍ថាវរៈនេះនៅមុំនេះ ហើយវរៈនោះនៅកន្លែងនោះអីចឹងទៅសំអាតឲ្យគ្រប់មុខសញ្ញា ។

**ស៊ីវ:** ហើយអាពាក្យបោសសំអាតនិងមែនទែនទៅមានន័យថាយ៉ាងម៉េច?

**ម៉ឺត:** គេបោសសំងាតនិងមានន័យថាឲ្យមកក្រោយទាំងអស់ គេស្រណុកធ្វើការ ។

**ស៊ីវ:** បើតាមខ្ញុំយល់វាពីរយ៉ាងណោះពូ អាមួយបោសសំអាតនិងមានន័យថាចង់ជំលៀសប្រជាជនចេញ ងាយស្រួលធ្វើការងារនៅក្នុងទីក្រុងអានិង១ ប៉ុន្តែវាមានមួយផ្សេងទៀតដែលថាដកប្រជាជនជំលៀសប្រជាជននិងឲ្យនៅតាមមូលដ្ឋានហ្នឹង ឬឲ្យចេញបណ្តោះអាសន្ននិងណា អានិងខ្ញុំមិនទាន់លើកទេប៉ុន្តែក្នុងពេលដែលជំលៀសប្រជាជន ក៏មានការចាប់ពួកទាហានលន់ នល់ដែរ ចាប់ដើម្បីកម្ទេចហ្នឹង អានិងជាការបោសសំអាតមួយដែរ?

**ម៉ីតៈ** បា!អានិងក៏នៅក្នុងការបោសសំអាតដែរ ជួនកាលដូចថាមានមកអីចឹងទៅ យើងដូចថាខ្ញុំក៏ដោយ គេក៏ដោយ គេជាអ្នកដាច់ខាតគេមានកំហឹងគេទៅ តែបើអ្នកអត់មានកំហឹងគេ ថាដូរខោរអាវទៅហើយមកក្រោយប្រជាជនអីចឹងទៅណា អានិងវាមានអីចឹងដែរ ។

**ស៊ីវៈ** គឺថាវាមានបញ្ហារផងនិងបញ្ហាផ្ទាល់ខ្លួនផង វាមានទាំងពីយ៉ាងហ្នឹង?

**ម៉ីតៈ** បាទ!

**ស៊ីវៈ** អីចឹងបានថាអារឿងសម្លាប់នាយទាហាន លន់ នល់ហ្នឹង សម្លាប់និងដោយសារមានបញ្ហារខ្លះ សម្លាប់ដោយសារមានការខឹងខ្លួនឯងផ្ទាល់ខ្លួនលើសពីការដែលគេ ឲ្យធ្វើនិងខ្លះដែរ?

**ម៉ីតៈ** អានិងវាមាន ប៉ុនតែបើយើងមិនធ្វើតែគេដឹងក៏អត់បានដែរ ។

**ស៊ីវៈ** យើងមិនធ្វើយ៉ាងម៉េច?

**ម៉ីតៈ** បើយើងមិនធ្វើគឺគេត្រូវតែធ្វើយើង ។

**ស៊ីវៈ** គឺថាបើយើងមិនកម្ទេចពួកមានបណ្ដាសក្តិពួកទាហានលន់ នល់ហ្នឹង គេនិងសម្លាប់យើងដែរ?

**ម៉ីតៈ** បា!អានិងគេថាយើងអត់ដាច់ខាត ។

**ស៊ីវៈ** ហើយបញ្ហានឹងវាធ្លាប់មានតាំងពីសង្រ្គាម៥ឆ្នាំមក ឈ្លើយសឹកអីដែលចាប់បានក្នុងពេលសង្រ្គាម៥ឆ្នាំនៅឡើយមិនទាន់១៧ មេសា ហ្នឹងណា ចុះបើឧបមាថាបើចាប់បានទាហានឬក៏នាយទាហានលន់ នល់ គោលដៅមាគ៌ារបស់គេចំពោះទាហាន លន់ នល់ និងយ៉ាងម៉េចដែរ នៅក្នុងសង្រ្គាម៥ឆ្នាំហ្នឹង?

**ម៉ីតៈ** កាលក្នុងសង្រ្គាម៥ឆ្នាំ និងខ្ញុំក៏អត់បានដឹងដែរបង ជួនកាលទៅចេះតែដើរតាមអ្នកធំព្រោះ អីខ្ញុំចេះតែដើរតាមអ្នកធំ ជួនកាលនៅតែកន្លែងនិងគេអ្នកមុខនិងគេចេះតែធ្វើទៅ ខ្ញុំអត់ សូវបានទៅសង្កេតសង្កាតអីដូចគេអីចឹងទេ ។

**ស៊ីវៈ** ពីព្រោះតាមដែលខ្ញុំសម្ភាសន៍គេមកវាមាន វាមានខុសៗពីគ្នា កន្លែងខ្លះឈ្លើយសឹកដែលគេចាប់បាននិងជាកូនទាហានធម្មតាគេគ្រាន់តែប្រមូលម៉ុទេអប់រំទេ កន្លែងខ្លះគឺថាមានការសម្លាប់នៅក្នុងពេលសង្រ្គាមនៅឡើយទេ មិនទាន់ចប់សង្រ្គាមទេ កន្លែងខ្លះនិងនៅក្នុងបញ្ហាសម្លាប់និងសម្លាប់តែនាយទាហានជាន់ខ្ពស់ទេ បុណសក្តិល្មមៗក៏គេទុកដែរ ហើយ

ខ្ញុំឆ្ងល់ថានៅក្នុងកងពល១២ហ្នឹង តើគេធ្វើយ៉ាងម៉េចដែរនៅក្នុងអង្គភាពហ្នឹង កងពល១២ហ្នឹង ពីព្រោះខ្ញុំយល់ឃើញថាវាមានខុសៗគ្នាដែរនៅក្នុងកងពលនិងវាមិនអត់ទេ វាដោយមេដែរ វាដោយរឿងជាក់ស្តែងដោយគេជួបប្រទះនៅក្នុងសមរភូមិវាមានខុសៗគ្នា?

**ម៉ែត:** កាលនិងវាតែងតែមានហើយ រឿងធ្វើសង្គ្រាមវាតែងតែមានហើយ ព្រោះអីជួនកាលយើងជាអ្នករំដោះ ។

**ស៊ីវៈ** គេជាពួកបក្សអកប្បកិរិយា?

**ម៉ែត:** គេថាបានឈ្លើយ បានឈ្លើយសឹកមក ដល់តែពេលដែលបានមកគេមិនទាន់ធ្វើអីយើងទេណា ឲ្យយើងធ្វើស្រែអីនៅក្នុងសមរភូមិក្រោយ ប៉ុនមកតែមួយដុំទេណា ប៉ុនមួយចំនួននោះវាមានខ្លាំងអីអ៊ីចឹងទៅគេសំលេះចោលទៅ អានិងវាអ៊ីចឹងតាមយល់របស់ខ្ញុំ តែបើយឲ្យឃើញជាក់ស្តែងនៅនិងភ្នែកនោះវាអត់ទេ គេអ្នកធំអ្នកបងគេតែងតែមិនឲ្យយើងដឹងហើយ គេឲ្យទៅហួសៗហើយ ដឹងនិងគឺឃើញតែគេចងមកខាងសមរភូមិក្រោយហើយរំដោះបានហើយ ។

**ស៊ីវៈ** ហើយបើតាមពូយល់តាមបាន់ស្មាននិង អារឿងនិងធ្វើខាងក្របខ័ណ្ឌផ្ទៃក្នុងរបស់កងពលទេ មិនមែនបញ្ជូនទៅខាងសន្តិសុខអីដោយឡែក សន្តិសុខរបស់តំបន់សន្តិសុខរបស់ស្រុកនិងគឺថាធ្វើក្នុងក្របខ័ណ្ឌរបស់កងពលនិងតែម្តង?

**ម៉ែត:** ព្រោះអីកងពលប្រគល់មកឲ្យកន្លែងតំបន់ ប្រគល់មកឲ្យតំបន់ហ្នុង ព្រោះអីកងពលថែរក្សាអត់កើតទេ ពេលនិងមានពេលណាថែរក្សាមានតែពេលគិតពីសមរភូមិមុខហ្នឹង ដល់តែពេលអ៊ីចឹងទៅប្រគល់ទៅឲ្យតំបន់វិញ ។

**ស៊ីវៈ** អ៊ីចឹងបើចាប់បានហើយបញ្ជូនទៅសមរភូមិក្រោយ អារឿងទុកប្តុកម្មេចនិងនៅលើតំបន់ទេ?

**ម៉ែត:** បាទ! អានិងតំបន់និងក៏ឲ្យពត៌មានមកដែរ អានេះតាមខ្ញុំយល់ ទាល់តែខាងនោះឲ្យព័ត៌មាន មកបានខាងនេះគេហ៊ានដែរ ។

**សុជាៈ** ខាងភូមិភាគឲ្យព័ត៌មានមក?

**ម៉ែត:** បាទ! តំបន់និងក៏មិនហ៊ានអនុញ្ញាតដែរ ព្រោះអីវាមានថ្នាក់វា ។

**ស៊ីវៈ** អ៊ីចឹងបានសេចក្តីថាត្រឹមថ្នាក់តំបន់និងក៏មិនហ៊ានសំរេចដែរ?

**ម៉ើតៈ** បាទ!

**ស៊ីវៈ** ទាល់តែឆ្លង ឬក៏មានសេចក្តីសំរេចពីភូមិភាគមក?

**ម៉ើតៈ** បាទ!

**ស៊ីវៈ** ហើយមិញនិងពូមានប្រសាសន៍ថាក្រោយ១៧ មេសានិង ពូចូលទៅដល់សាលារបស់កងពល សាលាបញ្ចេកទេសនិងណា?

**ម៉ើតៈ** ទេអត់បានចូលទៅទេ សាលាបច្ចេកទេសនិងនៅតាខ្មៅយើងនេះទេណា ខ្ញុំចូលនៅរៀនហ្នឹង ។

**យាន៖** ៧០៣?

**ម៉ើតៈ** បា!៧០៣ ។

**ស៊ីវៈ** ហើយនៅក្នុងប្រវិត្តិរូបរបស់លោកពូនិងណា គេដាក់ថាអង្គការបានបញ្ជូនគាត់ទៅរៀននៅសាលាបញ្ចេកទេសយោធា កន្លែងសាលាកងពល៧០៣ហ្នឹង រៀន៦ខែក្រោមឈ្មោះទុយ ឈ្មោះយែមហើយនិងឈ្មោះប៉េងមួយ?

**ម៉ើតៈ** អ្នកដែលបង្រៀននៅសាលានិងហ្នេ៎ មានតាប៉េងមួយ តាយែមមួយទៀត ហើយមិនដឹងជាមានឈ្មោះអីទៀតទេកាលហ្នឹង វាភ្លេចដែរហើយដឹងតែយែមទេ យែមអីក៏ចែមមិនដឹងទេ ។

**ស៊ីវៈ** អាយែមនិងយ៉ាងម៉េចដែរ?

**ម៉ើតៈ** យែមនិងមិនដឹងម៉េចទៀត ទាល់តែខ្ញុំចេញពីសាលាបច្ចេកទេសនិងគេចាប់ផ្តើមបញ្ជូនខ្ញុំថាទៅឲ្យរៀននយោបាយទៀត ។

**ស៊ីវៈ** ហើយទុយនិងក្រោយមកធ្វើជាអ្នសួរចម្លើយនៅស-២១ឬក៏ទុយមួយផ្សេង?

**ម៉ើតៈ** ទុយ!

**ស៊ីវៈ** ទុយដែលបង្រៀននៅសាលាបច្ចេកទេសហ្នឹង?

**ម៉ើតៈ** អត់មានឈ្មោះទុយទេ សាលាបច្ចេកទេសអត់មានទុយទេ ។

**ស៊ីវៈ** អ៊ីចឹង ចុះប៉េង?

**ម៉ើតៈ** ប៉េងក៏អត់មានបាននៅសាលាបច្ចេកទេសនិងដែរ ។

**ស៊ីវៈ** អ៊ីចឹងចាំតែឈ្មោះយែមនិងមួយ?

**ម៉ើតៈ** បា!យែមហើយនិងប៉េងហ្នឹង មិនដឹងជាទៀតទៅដល់ណាទៅនៅឯណាអី មិនដឹងជាស្លាប់ឬក៏រស់ទេអត់ដឹងទេ ។

**ស៊ីវៈ** ហើយសាលានិងជារបស់កងពលទេ មិនមែនជារបស់សេនាធិការ?

**ម៉ើតៈ** របស់កងពល ។

**ស៊ីវៈ** លើកមុនយើងមានសួរថាសាលាបច្ចេកទេសនិងមានគ្រូបង្រៀនចិនទេ?

**សុជាៈ** នៅសាលាបច្ចេកទេសនៅតាខ្មៅហ្នឹង មានជនជាតិចិនប៉េកាំងនិងទេ?

**ម៉ើតៈ** ដូចជាអត់មាន ។

**ស៊ីវៈ** ខ្មែរយើងជាអ្នកបង្រៀន?

**ម៉ើតៈ** បា!

**ស៊ីវៈ** ពីណាខ្លះជាអ្នកបង្រៀន?

**ម៉ើតៈ** មានតែបងយែមបងប៉េងហ្នឹង គេជាអ្នកគណៈសាលា ។

**ស៊ីវៈ** ចេញពីអានោះហើយបានទៅធ្វើការនៅក្របខ័ណ្ឌនៅស-២១អ៊ីចឹង?

**ម៉ើតៈ** បា!ដល់តែពេលគ្រាន់តែចេញពីសាលានិងទៅ គេឲ្យយើងរៀននយោបាយ រៀននយោបាយនិងគេនិយាយពីរឿង អាដែងថាក្មេចដែរខ្ញុំកាលហ្នឹង គេបង្រៀនពីនយោបាយនិងគោលជំហរសតិអារម្មណ៍គេនិងណា ការចាត់តាំងរបស់បក្សគេនិងណា មានអ៊ីចឹងហើយធម្មតាខ្ញុំចេះតែរៀនហើយ បើមនុស្សមិនដឹងទិសតំបន់អីនៅឯណាវាមិនសូវជាចេះអក្សរដែរចេះតែទៅនិងគេទៅ រៀនបណ្ដើរងក់បណ្ដើរ ។

**ស៊ីវៈ** ហើយអ្នកណាគេជាអ្នកបង្រៀនហ្នឹង?

**ម៉ើតៈ** បង្រៀននិងបងហួរ បងហួរយើងដែលខ្វាក់ភ្នែកនិងណា គាត់បង្រៀននៅកន្លែងផ្សារថ្មីវាមិនដឹងជានៅកន្លែងណាទៀតទេ ។

**ស៊ីវៈ** អានិងនៅក្នុងក្របខ័ណ្ឌកងពល៧០៣នៅឡើយឬក៏ចូលទៅក្នុងស-២១ហើយ?

**ម៉ើតៈ** កន្លែងនិងចាន់ដឹងថាចូលទៅស-២១ ឬនៅកន្លែងកងពលទេអត់ដឹងហ្នង និងគេហៅពីនេះចូលទៅនិងអត់ដឹងនៅកន្លែងណាទិសតំបន់កន្លែងណា ដល់តែពេលរៀនហើយអីហើយ គេចាប់ផ្ដើមរើសយើង រើសនិងក៏មិនដឹងថាគេរើសយកទៅធ្វើអីដែរ អត់ដឹងទៀត រើសនិង

គេហៅយើងចូលទៅតាមអង្គភាពហ្នឹងហើយដាក់ឡានទៅ ដាក់ឡានទៅគេអត់គាន់និយាយ អំពីថាយើងធ្វើការអីធ្វើការអីមួយៗគ្មានទេ ចូលទៅដល់កន្លែងនិងគេឃើញហ្នង ឃើញ អាដែងថា អ្នកទោសនិងគេចង់មុខចង់អី គេបណ្តើរ ។

**ស៊ីវ:** កន្លែងដាំដែងហ្នឹង?

**ម៉េត:** បា!កន្លែងដាំដែង គុកចង់តែកន្លែងហ្នឹង កន្លែងសេនាធិការកន្លែងហ្នឹង ។

**សុជា:** នៅខាងណាភ្នំពេញ?

**ម៉េត:** នៅក្នុងភ្នំពេញនិងហ្នង ។

**ស៊ីវ:** នៅម្តុំណាពូ?

**ម៉េត:** កន្លែងនិងមានកន្លែងយន្តហោះមួយដែលចុះទុកនៅកន្លែងនិងមួយ មិនដឹងជាយន្តហោះអី កន្លែងសេនាធិការដាំដែងនិងហ្នង ។

**សុជា:** ពូស្គាល់ផ្សារថ្មីទេ?

**ម៉េត:** ផ្សារថ្មីស្គាល់ ប៉ុនអាកន្លែងមុនដំបូងគាណាតគាត់នៅ ។

**សុជា:** នៅខាងណាផ្សារថ្មី?

**ម៉េត:** ខ្ញុំដូចជាច្រលំដែរហ្នឹង ទៅរក ។

**ស៊ីវ:** ជាប់ផ្លូវធំទេ?

**ម៉េត:** និងអត់ទេចូលទៅក្នុងបន្តិច ប៉ុនវាមិនដឹងផ្លូវធំនៅកន្លែងណាៗអីទេ វាលែងដឹងអាផ្លូវក្នុង ទៀតនិងណា ភ្នំពេញអត់ដែលដើរសប់ផង ។

**ស៊ីវ:** ប៉ុន្តែកន្លែងនិងគាណាតនៅ?

**ម៉េត:** បា!គេថាកន្លែងសេនាធិការអីគេហ្នឹង ។

**ស៊ីវ:** គាណាតនិងដកគាត់ចេញពីកងពល ហើយដាក់គាត់ចូលទៅក្នុងសេនាធិការវិញ នៅក្រោមខ្សែវិញ?

**ម៉េត:** បាទ!

**ស៊ីវ:** អីចឹងហាក់ដូចជាបានសេចក្តីថា កន្លែងគុកដាំដែងនិងជាគុករបស់សេនាធិការទេ វាអាចអីចឹងទេ?

**ម៉ឺត:** បាៗ!នៅកន្លែងនិងហើយដល់តែនៅកន្លែង ខ្ញុំវាអត់ដឹងអីពេលប្រជុំគេដាក់ឲ្យរៀនសូត្រ នៅកន្លែងហ្នឹង គេហៅពួកអ្នកទៅនិងវានឹកឃើញថាក្នុងចិត្តនិងភ័យ មិនដឹងគេហៅយើងយកទៅដាក់គុក ឬធ្វើនយោបាយយើងដើម្បីយើងរៀនសូត្រហើយ យើងទៅធ្វើការងារនៅកន្លែងហ្នឹងក៏វាអត់ទាន់ដឹងដែរ ទៅដល់ភ្ជាមគេក៏ហៅប្រជុំក៏ឡើងទៅ កាលនិងមានឃើញមានឌុច តែកាលនិងខ្ញុំក៏អត់ទាន់ស្គាល់ដែរ ។

**ស៊ីវ:** នៅកន្លែងគុកផ្សារថ្មីហ្នឹង?

**ម៉ឺត:** បា!កន្លែងសេនាធិការនិងណា ឌុច ហូហើយនិងតាណាត ទាំង៣នាក់និងខ្ញុំក៏នឹកឃើញចូលទៅមិនដឹងជាម៉េចទេពួកយើងព្រោះបានចូលកន្លែងហ្នឹង ដល់គេនបង្រៀននយោបាយយើងនិងដើម្បីគេបំពាក់បំប៉នយើង ហើយគេថាបក្សអត់មានយកយើងមកធ្វើអីទេ កុំភ្ញាក់កុំផ្អើលកុំភ័យឲ្យសោះ គេមកឲ្យយើងយាមអ្នកទោស សួរយើងមុនដំបូងយើងអត់ដឹងពីរឿងហេតុផលអី អ៊ីចឹងថ្ងៃនិងខ្ញុំក៏ចូលមុនដំបូងគេ គេអត់សួរដែរថាយើងថ្មីចូលយាមនិងក៏រួចម្នាក់ ។

**យាង:** អ្នកទោសរត់រួច?

**ម៉ឺត:** បាទ! អ្នកទោសរត់រួច កាលនិងខ្ញុំក៏អត់ដឹងថារឿងនិងវាម៉េចៗ ខ្ញុំចាក់សោរឲ្យគេបត់ជើង អ្នកទោសនិងក៏រត់រួចទៅ បាត់ប៉ុន្មានទេដូចជាពីរយប់បីថ្ងៃណោះ ដល់ហើយបានតាហូ, តាឌុចមកដល់បើរួចហើយយកមិត្តនិងចូលទៅទុកធ្វើអី ខ្ញុំក៏ភ័យបានតាណាតគាត់ថាកុំអាលប្រឡាតពេក តាណាត គាត់ថាបន្ទំទៅណារកសិនព្រោះគ្នាថ្មីថ្មោងអត់ដឹងអីបានរាងអ៊ីចឹងទៅទប់ស្កាត់រកឃើញអ្នកទោសនិងមកវិញ ។

**ស៊ីវ:** សុំសួរបន្តិចអ្នកទោសនិងជានាយទាហានលន់ នល់ ឬរាជការលន់ណុល ឬក៏ជាអ្នកដែលចាប់នៅក្នុងជួរបក្សដិវត្តន៍ដែរ ឬក៏ឡាយឡំគ្នាយ៉ាងម៉េច?

**ម៉ឺត:** ខ្ញុំអត់បានស្គាល់អាកន្លែងថាជាទាហានលន់ នល់ ឬវិស្សុករឬខាងស៊្ឋីៗមិនដឹងទេ ខាងស៊្ឋីក៏អត់ដឹងដែរ ។

**សុជា:** តែគាត់ចង់សួរថាបេះ អ្នកទោសដែលត្រូវគេយកទៅដាក់នៅគុកជាំដេងនិងកន្លែងពូយាមនិងណា ពេលនិងមានចាប់ផ្តើមមានចាប់ជួរខ្មែរក្រហមដែលនៅក្នុងបក្សដិវត្តន៍និងនៅ ឬក៏ពួកនិងសុទ្ធតែពួកដែលជាប់និងនាការពីលន់ណុល ទោះបីជាវិស្សុករក៏ដោយ?

**ម៉ឹតៈ** ខ្ញុំនិយាយនិងវាចំរុះ ជួនកាលយកពីតំបន់ទៅ ចាប់បណ្ដើរៗដូចសុខនិងតាកាតអីជាចៅហ្វាយស្រុកអីនិងចេះតែទៅបណ្ដើរៗហើយអាហ្នឹង ហើយចំរុះគ្នាជាមួយខាងលន់ នល់ ប៉ុនខ្ញុំវាមិនដឹងថាអាមួយណាជាអី អាដែងពួកខាងជួរលន់ នល់មួយណាក៏អត់ដឹងដែរ តែចូលដល់សុទ្ធតែស្រព្រិះស្រព្រុះអស់ហើយ អីចឹងខ្ញុំក៏មិនអាចសន្និដ្ឋានបានដែរកន្លែងហ្នឹង ។

**ស៊ីវៈ** ប៉ុន្តែពេលដែលឈ្មោះហូ និងបង្រៀននិងណា ក្នុងពេលនោះគាត់មាននិយាយពីបញ្ហាខ្មាំងបង្កប់ផ្ទៃក្នុងហើយឬក៏មិនទាន់និយាយទេ?

**ម៉ឹតៈ** កន្លែងនិងគាត់គ្រាន់តែបង្រៀន គាត់បង្រៀនជាដូចថាគោលនយោបាយបាយបណ្ដុះសតិអារម្មណ៍កុំឲ្យយើងភ្លើតភ្លើងទៅតាមមនោសញ្ចេតនា ដូចថាយើងមិនដែលមានសម្ភារះយើងមិនដែលមានសម្ភារះដូចជារាជ្យ ដូចជាអាដែងថាខបករអ៊ីមួយដែលយើងមិនដែលមានអីចឹងអាកន្លែងនិងគេមិនឲ្យយើងយក យើងទប់គោលជំហរស្រើញអីចឹងដូចស្រីពេស្យាអីដើម្បីមកបង្កប់នៅក្នុងនិងដើម្បីអូសទាញយើង អានិងកន្លែងនិង១ ទី២គេឲ្យយើងពង្រឹងគោលជំហសតិអារម្មណ៍ដើម្បីការពារខ្មាំង ឲ្យការពារខ្មាំងកុំឲ្យខ្មាំងរត់ កុំឲ្យខ្មាំងចងករសំលាប់អានិងទី២ ទី៣គឺថាចាត់តាំងរបស់គេគឺថាគេចាត់តាំងទៅកន្លែងណាមិនឲ្យយើងនេងរុញរាពីការងារ គេថាបក្សដិវត្តន៍ណាអានិងវាអីចឹងទេ ។

**យាងៈ** ពូនិយាយមិញថាពួកប្រហែសធ្វើអ្នកទោសរត់រួចម្នាក់និង នៅក្នុងក្រុមពូដែលយាមនិងមិនមែនមានតែម្នាក់ទេ តើមានប៉ុន្មាននាក់?

**ម៉ឹតៈ** យាមនិងហ្ន៎ មានតែម្នាកឯងទេ ម្នាក់ឯងនិងវាមានបីកន្លែងនេះ កន្លែងនេះមួយកន្លែងនេះមួយ វាមានបីអីចឹងហើយបន្ទន់នៅត្រង់នេះ ដល់ហើយខ្ញុំក៏ចាក់សោរឲ្យចូលទៅក៏ដើរចេញដូចថាទៅរកហូបទឹកហូបអីអីចឹងទៅណា ដល់ចូលទៅវិញវាបាត់ផ្ទោះរបងវាមិនដឹងជាចូលទៅកន្លែងណាចេញកន្លែងណា កន្លែងនិងលឺសូរគេថាមានពេទ្យមុនីវង្ស កន្លែងនិងលឺគេថាជាប់ពេទ្យមុនីវង្ស ។

**ស៊ីវៈ** អីចឹងបានន័យថានៅខាងណាពេទ្យមុនីវង្ស?

**ម៉ឹតៈ** កន្លែងខ្ញុំមិនដឹងទេព្រោះអីវា វាត្រូវអានិងវាបែរមុខទៅកើត បើនិយាយទៅនៅក្រោយពេទ្យមុនីវមុខទៅកើត បើនិយាយទៅនៅក្រោយពេទ្យមុនីវង្ស ។

**យាន:** ចុះពូពីរនាក់ទៀតនោះគេមានទោសដូច ខុចថាចាប់យកទៅដាក់គុកដាក់អីទេ?

**ម៉ែត:** គេគ្រាន់តែថាដូចតាណាត គាត់និយាយអ៊ីចឹង គាត់ថាកុំអាលយកគេទៅណា តែបើរកមិនឃើញខ្ញុំត្រូវបាត់ វាមិនតែមួយដងនិងទេវាច្រើនសារហើយ តែដូចថាអាយុជីវិតខ្ញុំមាន គេមកជួយ ជួយខ្ញុំអ៊ីចឹងទៅចេះតែបណ្ដែតៗទៅរហូតបានមកដល់សព្វថ្ងៃ ។

**ស៊ីវៈ** ក្នុងពេលបង្រៀននិងគេថាឲ្យកចិត្តទុកដាក់ទៅលើបញ្ហាខ្មាំង និងមានអធិប្បាយថាខ្មាំងនិងជាស្អីដែរ ខ្មាំងវាមានច្រើនប្រភេទ?

**ម៉ែត:** ខ្មាំង១គឺគេថាខ្មាំងបង្កប់ផ្ទៃក្នុង ខ្មាំងទី២គេថាយើងចាប់ពីសង្គ្រាមលន់ណុលមកអ៊ីចឹងក៏ជាខ្មាំងដែរ ខ្មាំងបើនិយាយទៅឲ្យតែអ្នកណាខុសសុទ្ធតែជាខ្មាំង ឲ្យតែខុសខ្មាំងហើយ ។

**សុជា:** ខុសនិងអីគេពូ?

**ម៉ែត:** ខុសនិងនៅលើមាគ៌ាបក្សដិវត្តន៍របស់គេ អានិងសុទ្ធតែជាខ្មាំងហើយអាហ្នឹង ខុសពីច្បាប់របស់គេដែកគេបង្រៀនពន្យល់យើងហើយហ្នឹង បើយើងចាកពីការងាររបស់គេអានិងក៏ជាខ្មាំងដែរ ។

**ស៊ីវៈ** តែបើនិយាយសរុបមកខ្មាំងនិងវាមានពីរយ៉ាង ខ្មាំងពីសង្គមចាស់ និងខ្មាំងដើរបង្កប់នៅក្នុងជួរបក្សដិវត្តន៍ហ្នឹង?

**ម៉ែត:** អានិងខ្ញុំក៏វាអត់ទាន់បានយល់ វាគ្រាន់ថាខ្មាំងវាមានច្រើនយ៉ាងណាស់ តែខ្ញុំស្ដាប់លឺគ្រាន់តែថាខ្មាំងៗ ដែលយើងអនុវត្តន៍នៅកន្លែងនិងហើយធ្វើការមិនកើតក៏គេហៅយើងខ្មាំងដែរ ។

**ស៊ីវៈ** ហើយកន្លែងដាំដេងនិងមានឃើញគេសរសេរថាដាំដេងទេ?

**ម៉ែត:** អត់ឃើញអក្សរបង អត់បានចូល ព្រោះគេអត់យើងចូលដងកាលហ្នឹង គ្រាន់ជួនកាលគេឲ្យយើងទៅធ្វើសេដ្ឋកិច្ចដាំស្វាយនិងចេះតែដាំទៅ ជួនកាលត្រូវឲ្យយើងមកធ្វើសេដ្ឋកិច្ចដាំបាយឲ្យពួកអ្នកធ្វើការនិងហូប ប៉ុន្តែមានអ្នកផ្សេងគេធ្វើផ្សេងទៀត គេមិនហ៊ានឲ្យយើងចូលកន្លែងនិងទេ គេខ្លាចយើងបំពុលអីទៅវាងាប់ខ្មាំងឬស្អី គេគ្រាន់តែឲ្យយើងដូចថាយកជញ្ជូនអីឲ្យគេអ៊ីចឹងទៅណា ។

**ស៊ីវៈ** ហើយចំពោះអ្នកទោសដែលនៅកន្លែងដំដេងនិង ខុចអីនិងរៀបចំឲ្យមានការសួរចំលើយទេ តើមានទេ?

**ម៉ៅត:** បាទ! បាទ! កាលពីដើមទីនិងមានតែវាមិនទាន់បានស្អួលស្អាស់ដូចកាល នៅទួលស្លែងទេ មាន ដូចថាអាទុយ, អាណាន, អាទិតអីអ៊ីចឹងទៅណា ។

**សុជា:** ចុះប៉ុនអីមានទេ?

**ម៉ៅត:** អាប៉ុននិងក៏មានដែរ មាននៅនិងដែរព្រោះវាចេញមកនិងនៅចំហៀងខាងនេះ គេអត់ទាន់ឲ្យយើងមានការសួរចំលើយអីដែរ ព្រោះយើងវានៅខាងភូមិភាគនិរតី អ៊ីចឹងគេយកខាងពួកឌុចមក ពួកអាឌុចមកខាងកំពង់ឆ្នាំងជាអ្នកសួរទៅ ព្រោះអីកាលនិងដំបូងវាមិនសូវជាមានពួកអាកាចអីជាអ្នកសួរទេ វាច្រើនតែពួកគេជាអ្នកចេះដឹង អ៊ីចឹងគេមិនទាន់ចាត់តាំងពួកអាអស់នេះទេ ហើយឆ្នាំប៉ុន្មានមិនដឹងទេគេឲ្យទៅនៅទួលស្លែងវិញ តែវាភ្លេចបាត់ទៅ ។

**សុជា:** អ៊ីចឹងខ្ញុំសួរពូពីរឿងនៅដាំដេងនេះបន្តិច នៅដាំដេងនិងឌុចនិងគាត់មានតួនាទីជាអីគេ?

**ម៉ៅត:** ឌុចនិងគឺថាគេរួមគ្នាជាមួយតាហូ បើនិយាយទៅគិតទៅគេជាអនុប្រធានតាណាត ។

**ស៊ីវ:** ឌុចនិងជាអនុប្រធានតាណាត?

**ម៉ៅត:** បាទ!ដល់តែយូរៗទៅតាណាតនិងគេដកចេញទៅឡើងហ្នង ។

**សុជា:** អានេះគិតទៅតាណាតនិងនៅសេនាធិការ នៅសេនាធិការដូចថាគាត់ក្តោបអ៊ីចឹងទៅវាមានផ្នែកផ្សេងៗគ្នា អាផ្នែកដែលចាប់ចងអាផ្នែកសំលាប់ចោលអីគឺនៅលើឌុច?

**ម៉ៅត:** នៅលើឌុច នៅលើឌុចសំខាន់គឺនៅលើពីរនាក់និងទេ ព្រោះតាណាតគាត់នៅកន្លែងសេនាធិការពិតមែន ប៉ុន្តែគាត់ក្តាប់រួមតែក៏មិនមែនគ្រប់គ្រងអារឿងអ៊ីចឹងៗទេ គាត់ធ្វើការងាររបស់គាត់ដូចថានៅលើអ៊ីចឹងទៅណា ។

**ស៊ីវ:** មិញនិងលោកពូមានប្រសាសន៍ថាមុនដំបូងឡើយ តាណាតជាប្រធានកន្លែងនិងហើយឌុចជាអនុប្រធានរបស់គាត់?

**ម៉ៅត:** ខ្ញុំវាគ្រាន់តែបានដឹងថាវានៅទាំងអស់គ្នានៅនិងទេ តាណាតនិងគាត់ជាប្រធាន ឬមិនប្រធានទេ ព្រោះអីគាត់នៅនិងសេនាធិការនៅហ្នឹង ។

**ស៊ីវ:** ហើយអ្នកទោសនិងពេលដែលសួរចំលើយហើយ សុំទោសយកទៅកម្ទេចចោលហើយ ឬពេលនោះមិនទាន់មាននយោបាយនិងទេ?

**ម៉ឺត:** កាលនោះអត់ទាន់ អ្នកល្អមៗដក់ទៅឲ្យនៅមួយកន្លែងតែយើងអត់ដឹងដែរ ទៅកន្លែងធ្វើស្រូវឬមួយកន្លែងសម្លាប់ មិនទាន់បានដឹងកន្លែងហ្នឹង អត់ទាន់បានដឹងទេមិនដឹងជាគេយកទៅកន្លែងណា គេជំលៀសយកទៅទុកឬមួយកន្លែងនិងវាប្រចុចញ្ចុច ព្រោះវាគៀកកន្លែងពេកបានជាគេយកទៅកន្លែងផ្សេងទៀតក៏វាមិនដឹង ខ្ញុំក៏អត់បានដឹងដែរកន្លែងហ្នឹង

**ស៊ីវ:** ដឹងតែថាមានគេយកចេញខ្លះ ប៉ុន្តែគេយកចេញឲ្យទៅធ្វើស្រែ ឬយកចេញនិងហើយសំលាប់បណ្តោយនិងនៅពេលនោះលោកពូអត់ដឹងទេ?

**ម៉ឺត:** កាលនោះវាមិនទាន់បានអាយុ២០អីឯណាផងនៅត្រឹមតែ១៩-១៨ឆ្នាំ ។

**សុជា:** ពូខ្ញុំសួរបន្តិចទៀត ពេលដែលពូនិយាយមិញនិងការចាប់ទៅដាក់គុកជាំដេជនិងវាចំរុះគ្នាអ្នកដែលមានជាប់បណ្តាសក្តិឬក៏នាការអីពីជំនាន់លន់ណុលមក ហើយនិងអ្នកដែលគេចាប់ពីតំបន់នេះទៅ ហើយពូបាននិយាយចេញឈ្មោះពីរគឺ ឈ្មោះសុខហើយនិងឈ្មោះកាតបើតាមដែលពូនិយាយហើយនិងខ្ញុំសម្គាសន់គេផ្សេងៗទៀតមក ថាកាតនិងគាត់ជាប្រធានយោធាស្រុកកោះធំ ហើយសុខនេះគាត់នៅតំបន់យើងនេះតំបន់២៥ បានន័យថាគេចាប់គាត់និងមុនចាប់ណាតឬក៏យ៉ាងម៉េច គឺថាចាប់កាត ចាប់សុខ និងមុនណាត?

**ម៉ឺត:** មិនដឹងថាចាប់ពីណាមុន អានេះគឺថាគ្រាន់តែដឹងដំណឹងថា តែចេញពីប្រកពខ្លួនឯងទៅគេអត់ឲ្យយើងឃើញទេ យើងគ្រាន់តែអាចថាដឹងដំណឹង ។

**សុជា:** តែដំណឹងនិងដឹងថាចាប់ផ្តើមចាប់ពីពួកតំបន់នេះទៅ?

**ម៉ឺត:** បាទ! ចាប់ពីតំបន់នេះទៅហើយ ។

**សុជា:** អីចឹងបានន័យថាចាប់មុនណាត ព្រោះអីពេលនិងណាតនៅធ្វើការ កាតនិងចាប់មុនណាតតែណាតនិងទាល់តែចូលឆ្នាំ៧៨បានគេចាប់ យើងចង់ដាងថាមូលហេតុអីបានជាគេចាប់កាតនិងសុខដែលជាគណៈតំបន់ហ្នឹង?

**ម៉ឺត:** ខ្ញុំអត់ដឹងដែរ ព្រោះអីខ្ញុំអត់បានដឹង បើខ្ញុំជាអ្នកសួរចំលើយខ្ញុំអាចដឹង តែនេះខ្ញុំគ្រាន់តែជាកងការពារអត់បានដឹងទេ បើគេជាអ្នកសួរចំលើយគេអាចដឹងនៅក្នុងឯកសារហើយអីចឹងខ្ញុំអត់បានដឹងរឿងរបស់គេទាំងអស់ ។

**ស៊ីវៈ** បានសេចក្តីអារឿងដែលលោកពូដឹងថា អារឿងចាប់សុខនិងកាតមកដាក់នៅកន្លែងដាំដេងនិងប្រហែលជាចុងឆ្នាំ៧៥ឬដើមឆ្នាំ៧៦ឬក៏នៅពេលណា ពូរកនឹកមើលតើក្រោយ១៧មេសាប៉ុន្មានខែឬជិតមួយឆ្នាំ ចូលឆ្នាំខ្មែរហើយឬនៅ?

**ម៉ើត:** មិនដឹងជាឆ្នាំណាទេនេះ ខ្ញុំវាពិបាកនឹកដែរ ។

**ឃាង:** ឥឡូវខ្ញុំសួរបេះវិញ ពេលដែលបែក៧៥មកពូគេឲ្យទៅរៀនបណ្តើរៗគេឲ្យមក ក្រោយមកគេឲ្យមកនៅដាំដេង រៀនយុទ្ធសាស្ត្រ៦ខែ ហើយបានមករៀននយោបាយ រៀនៗហើយបានគេឲ្យទៅនៅដាំដេង ពេលពូទៅដាំដេងនិងពូមានដឹងថាគេចាប់សុខ និងតាកាតហើយឬនៅ?

**ម៉ើត:** កាលនិងខ្ញុំចូលទៅក៏អត់ទាន់ដឹងដែរ ប៉ុនទាល់តែខ្ញុំនៅយូរបន្តិចបានដឹង ។

**ស៊ីវៈ** នៅប្រហែលបានប៉ុន្មាន?

**ម៉ើត:** នៅនិងអត់ដល់ឆ្នាំទេ នៅរយះអស់ហើយ៥ខែ ។

**សុជា:** អ៊ីចឹងនៅក្នុងចុងឆ្នាំ៧៥ហើយអ៊ីចឹង បើតាមប្រវត្តិរូបនិងថាបន្ទាប់ពីរៀនបច្ចេកទេសនិងចប់ខែ១១ឆ្នាំ៧៥ នៅក្នុងកងវរៈសេនាតូច១៨៣ជាមួយវឿន ហើយនិងតេងឡេងនៅក្រោយមកបានចាត់តាំងឲ្យធ្វើនិរសាជាមួយហ៊ុយហើយនិងស្រ៊ីហ្នឹង បើយ៉ាងឆាប់នៅក្នុងដើមឆ្នាំ៧៦ ពីព្រោះបើចូលនៅក្នុងកងវរៈសេនាតូច១៨៣និង នៅក្នុងខែ១១ឆ្នាំ៧៥ហើយនៅ១ខែអានិងចូលខែ១២ហើយអានិងចុងឆ្នាំហើយ ហើយចូលទៅកន្លែងដាំដេងនិងយ៉ាងឆាប់ខែ១ឆ្នាំ៧៦ ហើយពាក់កណ្តាលឆ្នាំ៧៦និងឬជិតចុងឆ្នាំនិង ឬពូផ្លាស់ទៅស-២១វិញ?

**ស៊ីវៈ** សុំសួរកាត់បន្តិចអារឿងចាប់សុខចាប់កាតនិងស្រុកជាមួយពេលគ្នានិងចាប់ឈ្មោះហួតសេហើយនិងឈ្មោះចំរើននិងដែរឬក៏ក្រោយឬក៏យ៉ាងម៉េច?

**ម៉ើត:** អត់ដឹង ។

**សុជា:** ពូដែលស្គាល់ហួត សេទេ?

**ម៉ើត:** អត់ស្គាល់ផង ។

**សុជា:** អ្នកដែលនៅស្អាងកោះធំយើងនិងច្រើនតែស្គាល់ឈ្មោះហួតសេហ្នឹង?

**ម៉ឺត:** គេធ្លាប់នៅជាមួយគេធ្លាប់ស្គាល់ យើងមិនដែលនៅជាមួយអត់ស្គាល់ទេ អាអ្នកធំៗនិង ជូនកាលគេមិនដែលឲ្យយើងឃើញផង ជូនកាលគេគេចខ្លួនគេត្រូវជាមួយអាដែងដែលគេ ធ្លាប់ស្គាល់គេស្គាល់ទៅ យើងមិនដែលនៅជាមួយអត់ស្គាល់ទេ ។

**ស៊ីវ:** ខ្ញុំសួរបែមួយចំហៀងទៀត អារឿងដែលចាប់សុខចាបកាតនិងបើតាមដែលចាំ បើតាម ដែកដឹងមុនប្ញក៏ក្រោយចាប់តាចេក តាចេកដាំសៀនគណៈតំបន់២៥ហ្នឹង?

**ម៉ឺត:** តាចេកដាំសឿនិងចាប់អីនៅឯណាអី ក៏អត់បានដឹងទៀត ។

**សុជា:** ពូថាបានទៅរៀននយោបាយជាមួយនិងហូជាមួយនិងឌុចអីហ្នឹង គោលនយោបាយគេវា មាន៣ចំនុច ដូចថាទទួលការចាត់តាំងពីបក្សដិវត្តន៍ពីអង្គការអីអ៊ីចឹងមក មិនឲ្យយើងភ្លើត ភ្លើនជាមួយសំភារៈដែលយើងរំដោះបានអ៊ីចឹង ប្ញក៏មិនឲ្យចាញ់ឃោសនាខ្មាំង បើសិនជា យើងដូចលោកពូអីគោរពអាគោលការណ៍វិន័យគេនិងមិនបាន តើគេមានដាក់ទណ្ឌកម្មដាក់ អីយើងម៉េចដែរ?

**ម៉ឺត:** អានិងគេមានហើយ បើយើងគោរបមិនបានពេលដែលយើងរៀនសូត្រកន្លែងណាទៀត គេឲ្យយើងធ្វើជីវទស្សទៀតហើយ ធ្វើជីវទស្សដើម្បីឆ្លងជីវទស្សនិងឲ្យយើងលើកឲ្យអស់ ឲ្យយើងលើកជីវទស្សនិងឲ្យអស់ អានិងវាដល់កំណត់គេដូចថាទី១មិនស្តាប់ទី២មិនស្តាប់ គេមានផែនការគេតទៅទៀត គេបញ្ជូនយើងទៅធ្វើស្រែវិញម្តង បញ្ជូនយើងឲ្យទៅធ្វើ ស្រែឲ្យយើងលត់ដំខាងអាដែងត្រូវស្ទូងស្រូវស្ទូងអីនិងណា ។

**សុជា:** តែអ្នកនិងគេចាត់ទុកជាខ្មាំងហើយ?

**ម៉ឺត:** អានិងក៏គេចាត់ទុកដូចជាខ្មាំងអ៊ីចឹង គ្រាន់តែវាមិនទាន់បានទោសធ្ងន់ ប៉ុនតែបើយើង មានទោសអីម៉្យាងទៀតអានិងទៅហើយ ។

**ស៊ីវ:** ម៉្យាងត្រឹមថ្នាក់ណា?

**ម៉ឺត:** ម៉្យាងទាល់តែយើងនិងគេនិយាយមិនស្តាប់ណែនាំមិនស្តាប់ អានិងតែគេចាប់ចងហើយ គឺ គេចងហើយគេលែងប្រលែងហើយ ។

**សុជា:** យកទៅធ្វើស្រែនិងគេអត់ចងទេ គេគ្រាន់តែបញ្ជូនចេញទេ?

**ម៉ឺត:** គេអត់ចងទេ គេគ្រាន់តែបញ្ជូនទេ ហើយប្រយ័ត្នទៅដល់ស្រែហើយបែរជាមិនកើតវិញ មកវិញចូលហើយ ។

សុជាៈ ចុះបើទៅស្រែយើងប្រឹងកែប្រែខ្លួនខ្លាំងយើងអាចឡើងវិញទេ ឡើងឋានៈវិញ?

ម៉ែតៈ មិនឡើងទេតែចេញមិនឲ្យចូលវិញទេ ។

ស៊ីវៈ អ៊ីចឹងខ្ញុំសូមចូលទៅដល់កន្លែងទួលស្លែងហ្នឹង ដែលគេហៅស-២១ ដែលគេហៅទួលស្លែងហ្នឹង ខ្ញុំចង់បញ្ជាក់លោកពូពីរចនាសម្ព័ន្ធនៅកន្លែងហ្នឹង ព្រោះខ្ញុំមើលក្នុងសម្ភាសន៍របស់លោកពូនិងសម្ភាសន៍របស់គេមួយចំនួនទៀត ខ្ញុំនៅតែមិនច្បាស់១០០ភាគរយតើរចនាសម្ព័ន្ធរបស់កន្លែងហ្នឹងយ៉ាងម៉េច នេះខ្ញុំគ្រាន់ពោលត្រួសៗប៉ុន្តែបើតាមខ្ញុំមើលក្នុងសម្ភាសន៍របស់លោកពូ បើតាមលោកពូដឹងគឺថានិយាយពីស-២១មានឌុចជាប្រធាន ហើយប៉ូ ហាក់ដូចជាអនុប្រធាន ហើយកម្មាភិបាលម្នាក់ទៀតហាក់ដូចជានៅក្នុងថ្នាក់ដឹកនាំស-២១ហ្នឹងមានឈ្មោះចាន់ហ្នឹងមួយ?

ម៉ែតៈ បាទ គាចាន់ហ្នឹង ។

ស៊ីវៈ អ៊ីចឹងឌុច ប្រធានប៉ូហ្នឹងអនុប្រធានហើយចាន់ ប្រហែលសមាជិក?

ម៉ែតៈ បាទ សមាជិកដូចជា ប៉ុនក៏ជាសមាជិករបស់គេដែរក្រុបខណ្ឌរបស់គេដែរ ។

ស៊ីវៈ អ៊ីចឹងប៉ុនប្រហែលជាគណៈកម្មាការដឹកនាំរបស់ស-២១ដែរ?

ម៉ែតៈ បាទ ចូលក្នុងហ្នឹងហើយដូចថាគេអ្នកសរុបចម្លើយអីហ្នឹង ។

ស៊ីវៈ ហ៊ុយទាំង២ទាំងហ៊ុយធំ, ហ៊ុយតូចតាមខ្ញុំយល់ចូលក្នុងគណៈកម្មាការដឹកនាំហ្នឹងដែរ ឬថ្នាក់ក្រោមទៀត?

ម៉ែតៈ ថ្នាក់ក្រោមទេហ៊ុយហ្នឹង ។ ប៉ុន្តែហ៊ុយធំខ្ញុំអត់បានដឹងដែរ គាត់នៅខាងព្រៃសខាងស្រែ គាត់អ្នកដឹកនាំដូចជាអ្នក អស់សិទ្ធិដឹកនាំធ្វើស្រែ ស្រូវអីចឹងទៅ ។ហើយដូចហ៊ុយនេះគាត់នៅទីនេះ ថ្នាក់ក្រោមហ្នឹងទៀតគេគ្រាន់ប្រគល់ភារកិច្ចថាទៅកន្លែងនោះ ហ្នឹងគាត់ចេះទៅហើយណា ។

ស៊ីវៈ ហ៊ុយធំហ្នឹង?

ម៉ែតៈ ហ៊ុយតូច គេថ្នាក់លើថាឥលូវមិត្តឯងទៅយកមនុស្សនៅកំពង់ឆ្នាំងអីចឹងទៅ ។

ស៊ីវៈ ហ្នឹងអ្នកចាប់?

ម៉ែតៈ បាទ ឲ្យទៅយក គេចាប់ហើយហ្នឹង មិនដឹងពីអ្នកណាចាប់ ។

**ស៊ីវៈ** ទទួលបញ្ជាពីខុច ពីហូ ថ្នាក់លើហ៊ុយតូចមានបេសកកម្មមានតួនាទីទៅចាប់គេតាមតំបន់តាមភូមិភាគ?

**ម៉ែតៈ** ទៅយកមក ។

**ស៊ីវៈ** ចំពោះហ៊ុយធំហ្នឹង ខ្ញុំចង់បញ្ជាក់ថាអ្នកខ្លះថាហ៊ុយធំ ខាងសេដ្ឋកិច្ចអ្នកខ្លះថាហ៊ុយធំទទួលកន្លែងព្រៃស ខ្លះថាហ៊ុយធំទទួលកន្លែងស៊ឹងបាគូ ស៊ឹងជ្រៅ តាមពិតអង្គភាពហ្នឹង?

**ម៉ែតៈ** ជាមួយគ្នាទាំងអស់ គេសហការគ្នា ។

**ស៊ីវៈ** អ៊ីចឹងកន្លែងសេដ្ឋកិច្ចនៅកន្លែងព្រៃស នៅក្នុងព្រៃសហ្នឹងមានដូចស៊ឹងជ្រៅ ស៊ឹងបាគូអង្គភាពតែមួយ?

**ម៉ែតៈ** ហ្នឹងជាមួយគ្នាបើនិយាយទៅ នៅក្នុងមន្ទីរស-២១ជាមួយគ្នាហ្នឹង ។ វាអត់មានបែងចែកទៅកន្លែងណាទៀតទេ ។

**សុជាៈ** តែពូដូចគាត់និយាយមិញ ថាហ៊ុយស្រែហ្នឹងខ្លះគេថាគាត់អ្នកខាងសេដ្ឋកិច្ច ក្នុងន័យហ្នឹងបានន័យថាអង្គភាពដែលព្រៃស នៅវត្តហារ ឬនៅស៊ឹងបាគូហ្នឹងគេបង្ករបង្កើនផលហ្នឹងយកមកផ្គត់ផ្គង់ទៅឲ្យខាងស-២១ ឬក៏ទៅណាផ្សេង?

**ម៉ែតៈ** នេះបើនិយាយរួមទៅថានៅក្នុងកង យកមកដាក់ក្នុងស-២១ក៏បាន យកទៅក្រៅប្រទេសក៏បាន ។

**សុជាៈ** ហ្នឹងបានន័យថាផ្គត់ផ្គង់ស-២១ផងនិងទៅក្រៅផង?

**ម៉ែតៈ** ទៅក្រៅផង ចំការនៅស-២១ហូបមិនអស់ទេតាមធ្វើនោះ មន្ទីរកន្លែងស-២១ធ្វើស្រូវពួកមន្ទីរស-២១ក៏ហូបមិនអស់ដែរ អ៊ីចឹងតាមមើលយកទៅក្រៅហើយ មិនដឹងទៅដល់ណាអីណាបើខ្ញុំអត់ដឹងបាយបិណ្ឌបាយបាតជាមួយតែគ្នាដែរ ។

**ស៊ីវៈ** អ៊ីចឹងបានសេចក្ដីថាក្រោមស-២១ហ្នឹង វាមានអង្គភាពសេដ្ឋកិច្ចមួយដឹកនាំឈ្មោះហ៊ុយធំហ្នឹង ហើយបើតាមសម្ភាសន៍ជាមួយលោកពូផងនិងជាមួយគេឯងផង ហាក់ដូចជាមានអង្គភាពមួយទៀតដែលនៅក្រោមស-២១ថាអង្គភាពសួរចម្លើយ ដោយឡែកក្នុងអង្គភាពសំរាប់សួរចម្លើយអ្នកទោស?

**ម៉ែតៈ** បាទហ្នឹងបើនិយាយទៅក្នុងស-២១ វាមានអ្នកប្រធានមន្ទីរមួយ មានអនុប្រធានហ្នឹងមក មានផ្នែក កងចាប់ទៅមានផ្សេងទៀតទៅ ហើយមានផ្នែកសួរចម្លើយមួយផ្នែក

ទៀតទៅ ហើយមកដល់កន្លែងយើងមានមួយផ្នែកអ្នកយាមទៀតទៅ ហ្នឹងមានថ្នាក់វា មកដល់ស្រែនោះវាមានថាអ្នកសេដ្ឋកិច្ចដូចហ៊ុយ ទទួលខុសត្រូវខាងធ្វើស្រែអីចឹងទៅ ហើយមានអ៊ីៗខុសគ្នាគេនិងបញ្ជូនពីហ្នឹងយកទៅ វៃចោលទៀតទៅហ្នឹងមានច្រើនប្រភេទ ណាស់ ។

**ស៊ីវៈ** អីចឹងបាទចង់បញ្ជាក់កន្លែងសេដ្ឋកិច្ចហ្នឹង វាហាក់ដូចជាច្បាស់ងាយយល់កន្លែងហ្នឹងសួរ ចម្លើយក៏ងាយយល់ដែរច្បាស់ហើយ ប៉ុន្តែដែលខ្ញុំមិនទាន់ច្បាស់ថា ក្រៅពីហ្នឹងមានអ្នក យាម មានអ្នកទៅទទួលអ្នកត្រូវគេចាប់ហ្នឹង មានអ្នកដែលយកគេទៅកំទេចហ្នឹងហើយ មានអ្នកដែលកំទេចគេក៏ដោយហ្នឹង មានអ្នកដឹកមានអ្នកចាប់ មានអ្នកយាមមាននិរសា មានអ្នកបើកបរហើយនិង មានអ្នកកំទេចគេដែរហ្នឹង ខ្ញុំចង់សួរបញ្ជាក់ទាំងយាមទាំងដឹក ទាំងចាប់ទាំងកំទេចហ្នឹង នៅក្នុងក្របខ័ណ្ឌរបស់កងការពារទាំងអស់ ឬក៏នៅក្នុងក្របខ័ណ្ឌ របស់កងការពារមួយចំនួន ហើយមួយចំនួនទៀតនៅដោយឡែកពីគ្នា?

**ម៉ើតៈ** ហ្នឹងបើនិយាយទៅ វាដោយឡែកពីគ្នា ជួនកាលអ្នកកំទេចវាច្រើន ដូចថាមេក្រុមដូចអា ស្រីគេអ្នកពេញសិទ្ធិ គេអ្នកធំៗ អីចឹងគេចេះតែទៅហើយ ។

**ស៊ីវៈ** ឈ្មោះស្រីហ្នឹង?

**ម៉ើតៈ** ស្រីដូចអាប៉េងអីហ្នឹងគេអ្នកពេញសិទ្ធិគេចូលបក្ស ដូចយើងអ្នកយាមម៉េចបាន ។

**ស៊ីវៈ** ប៉ុន្តែអ្នកយាមហ្នឹងនៅក្រោមកងការពារហ្នឹង?

**ម៉ើតៈ** បាទ ។

**ស៊ីវៈ** ច្បាស់ហើយអ្នកយាមនៅក្រោមកងការពារ?

**ម៉ើតៈ** បាទ ។

**ស៊ីវៈ** ហើយក្នុងអ្នកយាមហ្នឹងបែងចែកជាក្រុមទៀត?

**ម៉ើតៈ** អ្នកយាមហ្នឹងក៏បែងចែកជាក្រុម ។

**ស៊ីវៈ** ខាងថ្នាក់ខាងការពារហ្នឹងស្មើគ១?

**ម៉ើតៈ** ការពារហ្នឹង១ ការពារទី២ដូចថានៅក្នុងអគារសាលនៅកន្លែងក្នុងគុកហ្នឹងទី២ហ្នឹងកន្លែងចំរុះ ដូចកន្លែងយាម ។

**ស៊ីវៈ** ក្រុមផ្សេងៗហ្នឹង?

**ម៉ែត:** បាទក្រុមផ្សេង ។

**ស៊ីវ:** អ៊ីចឹងនិយាយមែនទែនទៅអ្នកណាប្រធានរបស់កងការពារហ្នឹង?

**ម៉ែត:** ប្រធានមានស្រី ។

**ស៊ីវ:** ស្រីខាងកងការពារហ្នឹង ធំហ្នុង?

**ម៉ែត:** បើនិយាយហ្នឹងប្រធានក្រុម ។

**ស៊ីវ:** ខ្ញុំចង់បញ្ជាក់ថាតើអ្នកណាទទួលរូម នៅកន្លែងការពារហ្នឹង?

**ម៉ែត:** ការពារហ្នឹងមានហ៊ុយនិងស្រី បើនិយាយទៅមិនទាន់បានដល់កង ប្រធានក្រុមគេអ្នកទទួលយាមហ្នឹងដូចជាអាចំរើន ប៉ុន្តែខ្លះវាធ្លាក់ខ្លះវាឡើង ខ្លះវាចុះទៅពិបាកថាណាស់វាម៉ៃ្វ ទឹកម៉ៃគោកត្រូវដកចេញ ដាក់ចូលៗវិញ ។ ហើយដូចមួយទៀតផល ច្រឹកគាត់អ្នកប្រធានហ្នឹងដែរ ។

**ស៊ីវ:** ខាងការពារហ្នឹង?

**ម៉ែត:** ខាងការពារហ្នឹង ខាងចាប់ចងក៏ចាប់ចង មិនដឹងមកពីណាអីណា ហើយកងការពារផ្នែកបងប៉េងគាត់ប្រធានខាងក្នុង ។ ក្នុងអគារយើងហ្នឹងប្រធានការពារ ។

**ស៊ីវ:** អ៊ីចឹងមានប្រធានការពារខាងក្រៅ ខាងក្នុង?

**ម៉ែត:** បាទ ។

**ស៊ីវ:** ខាងក្រៅហ្នឹង ចង់និយាយខាងក្រៅរបង?

**ម៉ែត:** ខាងក្រៅរបង ដូចថាអគារមានអ្នកទោសដូចថាចំរុះ អ៊ីចឹងអាក្រៅច្រើនអ្នកធំ ដូចគណៈភូមិភាគ តំបន់ដូចថាគេចាប់វៀតណាម បានអ៊ីចឹងគេយកមកដាក់ហ្នឹងដែរ កាលគេធ្វើទ័ពវៃស្វាយរៀងអីហ្នឹងគេយកមកដាក់ហ្នឹងដែរ ។

**ស៊ីវ:** ដាក់ខាងក្រៅមិនមែនដាក់ក្នុងរបង ដាក់តាមវិឡាផ្ទះថ្ម ផ្ទះល្វែង?

**ម៉ែត:** បាទក្រៅរបងយើងហ្នឹង និយាយទៅរបងអីចេះហើយនេះថ្នល់ជាតិចុះ នេះរបងកំពស់ហ្នឹងជុំវិញ អ៊ីចឹងមានអគារមានរបងមួយជាន់ទៀត ហើយនេះមានផ្ទះជុំវិញអគារយើងហ្នឹង ៗសុទ្ធតែគុកដូចគ្នា មិនដឹងកន្លែងណាគេយកសួរចម្លើយ មិនដឹងយកកន្លែងណាទៀតមិនដឹងទេជុំវិញសុទ្ធមានហើយគុកទាំងអស់មួយទីរួមទួលស្លែងហ្នឹងនោះ ដូចខ្ញុំនិយាយជាមួយតាប៉ាន់ថ្ងៃមុនយូរហើយមួយឆ្នាំជាង សម្ភាសន៍ជាមួយគាត់ថាគុកទួលស្លែងមិនមានតែ

អគារ៤ល្វែងទេ ផ្ទះដែលជុំវិញគុកហ្នឹងសុទ្ធតែគុកដែរ ។ ព្រោះមានគុកអ្នកធំមានគុកអ្នកតូច អ៊ីចឹងរឿងអ្នកធំ គេមិនអាចឲ្យមួយយាម២នាក់ ទៅ៣នាក់ទេ ។ មិនឲ្យយាមដូចយើងចល័តខាងក្នុងទេណា មួយម្នាក់ៗរហូត ។

**ស៊ីវៈ** ហើយឈ្មោះប៉េងហ្នឹងគាត់ទទួលខុសត្រូវ?

**ម៉ើតៈ** នៅខាងក្នុង ។

**ស៊ីវៈ** ហើយខាងក្រៅ?

**ម៉ើតៈ** ខាងក្រៅមានហ៊ុយមានអាស្រី ហើយបងផល ប្រើកហ្នឹងគាត់ចេះចល័តខាងណាក៏ទៅដែរ

**សុជាៈ** ផលហ្នឹងអ្នកមកពីកំពង់ឆ្នាំង?

**ម៉ើតៈ** ទេមិនដឹងកំពង់ឆ្នាំងអីណាគេគាត់ល្អិតខ្មៅ ។

**ស៊ីវៈ** ចុះថាអ្នកដែលចាប់ហ្នឹង ដែលចេញទៅក្រៅដើម្បីចាប់ហ្នឹងដែលទទួលពីភូមិភាគ?

**ម៉ើតៈ** ទទួលគ្រប់ភាគទាំងអស់គ្រប់ខេត្តទាំងអស់ ។

**ស៊ីវៈ** នៅក្រោមអង្គភាពការពារហ្នឹងដែរ ឬអង្គភាពមួយដោយឡែក?

**ម៉ើតៈ** អង្គភាពហ្នឹងបើនិយាយទៅជាមួយគ្នាទាំងអស់ ។

**ស៊ីវៈ** នៅក្នុងក្របខ័ណ្ឌរបស់កងការពារហ្នឹងដែរ?

**ម៉ើតៈ** ជួនកាលគេត្រូវមើលអ្នកណាចេះហ្នឹង វាឆ្លាតវាងវៃគេហៅទៅ អ្នកដែលមើកៗគេមិនហៅទៅទេអ៊ីចឹងគេមានរបស់គេមានពេញសិទ្ធិដូចថាអ្នកធំដូចឌុច ហ៊ីរ ដូចហ៊ុយ ដូចផលអ៊ីចឹងទៅណា ស្រីសួរថាតើអ្នកណាមួយដែលស៊ិតស្មាញជាងគេ អ៊ីចឹងគេមកហៅ ឥលូវហៅមនុស្សមកជូរម្នាក់នោះមកយាម អ៊ីចឹងឲ្យអ្នកហ្នឹងទៅគ្រាន់តែចាប់ ជួនកាលទៅដល់ភ្លាមគេចាប់មកឲ្យហើយ យើងគ្រាន់តែយកការពារតាមឡានមក ហ្នឹងវាអ៊ីចឹងទេហើយការងារទាំងអស់វាសឹងតែមូលគ្នាទាំងអស់ហើយសួរក៏ដូចការពារ ៗដូចអ្នកចម្លើយតែបើរឿងការពារអ្នកធំម្នាក់ៗហ្នឹង គឺមិនអាចឲ្យប្រឡូកប្រឡំទេ មិនអាចឲ្យស្គាល់ច្រើនទេ ។ ដូចខ្ញុំនៅយាមម្នាក់ គាត់ហ្នឹងគណៈភូមិភាគអ៊ីចឹងទៅណា ឬមួយកងពលឲ្យយាមតែម្នាក់ហ្នឹងទេ គេអត់មានឲ្យអ្នកណាចូលមកអើតទៀតទេ ។

**ស៊ីវៈ** ចុះចំពោះអ្នកកម្មុចនៅក្នុងកងការពារហ្នឹងដែរ?

**ម៉ឺត:** បើនិយាយនៅក្នុងកងការពារហ្នឹងទាំងអស់ៗគ្នា បើនិយាយរួមសួរចម្លើយក៏ចេះកម្មេចកងការពារក៏ចេះកម្មេចប៉ុន្តែវារើសដែរកន្លែងហ្នឹង គេរើសទៀតគេមិនមែនចេះតែឲ្យទៅៗ គេខ្លាចប៉ះពារបងប្អូនស្រស់កចិត្តទៅធ្វើម៉េច ហើយគេពិនិត្យមើលក្នុងប្រវត្តិរូបទៀត អ្នកណាដែលមានជាប់និន្នាការនយោបាយដូចជាបងធ្វើទាហានដូចខ្ញុំអ៊ីចឹង បងធ្វើទាហានកាលរាជលន់ នល់អ៊ីចឹង បងហ្នឹងៗ ដូចជាបងដែលគេយកមកដាក់នៅទួលស្លែងគេម៉េចឲ្យយើងទៅសម្លាប់ទៅធ្វើអ៊ីចឹង គេគ្មានឲ្យយើងធ្វើអ៊ីចឹងទេគេខ្លាចយើងស្គាល់រឿងខ្ញុំនិយាយទៅមានច្រើនសារហើយ តែវាមិនរាប់ដែរ ។

**ស៊ីវ:** អ៊ីចឹងសុំនិយាយសរុបបានសេចក្តីថាក្នុងអង្គភាព?

**ម៉ឺត:** ស-២១ទាំងអស់ ។

**ស៊ីវ:** ដែលធ្វើការពារហ្នឹងគេអាចចាត់តាំងថ្នាក់លើ ចង់និយាយដល់ហ៊ុយ ស្រី ដល និងប៉េងអាចចាត់តាំងឲ្យអ្នកខ្លះទៅធ្វើការងារខាងយាម អ្នកខ្លះទៅការងាររឿងចាប់ អ្នកខ្លះទៅធ្វើការងាររឿងកំទេច អ្នកខ្លះធ្វើការងាររឿងបើកបរឡានហ្នឹងៗ តាមដែលគេយល់ឃើញថាជ្រើសរើសយុទ្ធជនដែលធ្វើការនៅកន្លែងហ្នឹង ជួនកាលធ្វើជាអ្នកយាមជួនកាលចាត់តាំងឲ្យយកមក ជួនកាលអាចឲ្យទៅកម្មេច គេមើលប្រវត្តិរូបយើង គេមើលការងារយើងប្រវត្តិរូបរបស់យើងល្អ ការងាររបស់យើងល្អជួនកាលគេអាចទុកចិត្តយើងច្រើនរឿងដែលសម្ងាត់រឿងដែលពិបាកគេឲ្យយើងធ្វើៗ អ្នកដែលមានជាប់និន្នាការគេមិនសូវទុកចិត្តគេមិនសូវឲ្យធ្វើរឿងកម្មេច ឬមួយដើរចាប់?

**ម៉ឺត:** ហើយយាមហ្នឹងក៏គេមិនមែនថា ឲ្យយើងយាមម្នាក់ឯងអត់ទុកចិត្តយើងទេ គេនៅដើរចល័តទាំងយប់អ៊ីចឹង មើលខ្លាចទី១ងក់ ទី២យើងចាក់សោរព្រលែងហ្នឹងក៏មានដែរណា ។

**សុជា:** ពូនៅខ្វះចន្លោះមួយទៀតពីអ្នកសួរចម្លើយ ពីណាគេកាន់ការខាងសួរចម្លើយ?

**ម៉ឺត:** ហ្នឹងប៉ុន.......

**កាសែតទី២:**

**សុជា:** តទៅប៉ុនពូ?

**ម៉ែត:** ប៉ុននិងគេថាគេជាអ្នកប្រធានអ៊ីចឹង គេជាអ្នកសួរចំលើយគេជាអ្នកសរុបឯកសារអី ដល់ហើយអាទុយវាឋានៈជាប្រធានក្រុមគេក៏ប៉ុន្តែវាដូចថា ប្រធានក្រុមសួរចំលើយវាមានអាណា មានទុយមានទិត មានណានអីអ៊ីចឹងទៅ ឈិនមួយទៅអ៊ីចឹងវាអាចមានប្រធានក្រុមអ៊ីចឹងវាមានសមាជិកវាផ្សេងទៀត ចាត់តាំងគ្នាទៀតទៅណា ថាឥឡូវមិត្តឯងទៅយកអានេះ ដូចឌុចអីវាជាប្រធានវាថាឥឡូវ ទៅយកអានេះស្រគួរអ៊ីចឹងទៅណា ដល់អ៊ីចឹងវាទៅយកមក ដួនកាលពេលខ្លះវាមកសួរនៅកន្លែងយាម ព្រោះអីកន្លែងខ្ញុំយាមដូចថាខ្ញុំយាមម្នាក់អ៊ីចឹងទៅណា ដួនកាលគេអត់យកចេញទេ នៅនិងគេឲ្យយើងដើរចេញ ហើយគេនៅសួរហ្នឹង អានិងវាមានអ៊ីចឹង ។

**សុជា:** ការសួរនិងដូចខ្ញុំធ្លាប់ដឹងខ្លះមក គាត់ថាបើសិនជាសួរកម្មភិបាលតូចតាចធម្មតាៗ អានិងទុយអីជាអ្នកសួរ បើសិនជាសួរអ្នកធំដូចជាថ្នាក់វរៈកងពលកងអីអានិងពីណាគេជាអ្នកសួរទៅ?

**ម៉ែត:** ដួនកាលអាប៉ុន ដួនកាលឌុចអីមកដូចថាមុនដំបូងអីវាមកហើយណា មកនិងបើថាវាសួរនិងមិនចេញអីវាយការណ៍អីមិនអស់អ៊ីចឹងទៅ គេឲ្យពូកអាទុយ, អាណាន អាឈិនអីនិងដូចថា វាជាក្រុមក្តៅ វាមកសំឡុតហើយ ។

**សុជា:** ចុះពូខ្ញុំចង់សួរពីប្រព័ន្ធនៃការចាប់ពីខាងភូមិភាគពីតំបន់មកវិញ ពូនិយាយមិញថាដួនកាលហ៊ុយតូចយើងនិងហ៊ុយនៅកោះធំហ្នឹង ដួនកាលគាត់ទៅយកពីតំបន់មក ហើយតំបន់និងពូនិយាយមិញថាដួនកាលគេចាប់ទុកនៅតំបន់និងឬក៏នៅស្រុកនិងទៅណា ហើយយើងទៅយកមក អ៊ីចឹងការចាប់និងហាក់ដូចជាមានបណ្តាញគេមួយ ឌុចនិងជាអ្នកឲ្យពត៌មានគេទៅចាប់ឬក៏អ្នកណាផ្សេងឲ្យពត៌មានពីខាងតំបន់អីទៅចាប់?

**ម៉ែត:** អានិងនិយាយទៅវាមានតែឌុច ដូចថាឥឡូវវាមានចំលើយអ្នកនេះ ឧទាហរណ៍ដូចថាជាប់តាហុកមួយអ៊ីចឹង អ៊ីចឹងតាហុកគាត់ឆ្លើយដាក់ទៅ ឆ្លើយដាក់តាកាតតាអីអ៊ីចឹងទៅមើលសំនុំរឿងឯកសារហើយ ឡុងណោះចុះមកចាប់ទៀតទៅ អានិងវាបន្តគ្នាដូចជាត្រីស៊ីសន្ទូចអ៊ីចឹង ។

**សុជា:** អានិងវាដូចជាកាត់មុខ បើយើងនិយាយពីរចនាសម្ព័ន្ធគេគឺថា គណៈតំបន់វានៅក្រោមគណៈភូមិភាគ ហើយបើកាលណាយើងឌុចនេះទៅចាប់សុខថ្នាក់តំបន់ ចឹងបានន័យថាថ្នាក់

ភូមិភាគដូចតាណាតអីនេះ គាត់មានលទ្ធភាពឬក៏មានសមត្ថកិច្ចអីម៉េចដើម្បី អាចថាឃាត់ ឬក៏ចូលរួមក្នុងការចាប់និងដែរឬក៏អត់មានពាក់ពាន់ទេ ឬក៏ស-២១និងមានអំណាចផ្ទាល់ ទៅចាប់ អ្នកដែលត្រូវគេសង្ស័យឬក៏អ្នកដែលត្រូវគេចោទប្រកាន់និងនៅតាមតំបន់ដោយ គេផ្ទាល់ហ្នឹង អត់មានចាំបាច់ឆ្លងកាត់គណៈតំបន់គណៈភូមិភាគ?

**ម៉ីត:** បើខ្ញុំពិនិត្យទៅខ្ញុំក៏មិនអាចបានទៅដល់អីចឹងដែរ ប៉ុន្តែខ្ញុំអាចយល់ មុននិងគេទៅចាប់និងក៏ពិភាក្សាជាមួយអ្នកធំដែរ បើនិយាយរួមតាំងពីប៉ុលពតអីមកជាមួយគ្នានោះអាហ្នឹង មិនមែនអត្តណោមត្តខ្លួនគេទេ វារួមសហការណ៍តាំងពីលើមកដល់ទី១ទី២ទី៣អីចឹងទៅ មកដល់ត្រឹមអាដែងអាឌុចអាអីអីចឹងទៅ គេពិភាក្សាថាគ្នាថាណោះគ្រាន់តែឥក់ក្បាលអេនេះទៅយកទៅអានេះវាអីចឹងទេ ។

**សុជា:** អានេះខ្ញុំចង់សួរបញ្ជាក់និងដោយសារខ្លាចថា ក្រែងលរនៅស-២១និងបានសទទួលសិទ្ធិពិសេសពីគណៈមជ្ឈិម ថាស-២១និងអាចចាប់ចងអ្នកណាមួយចោទថាក្បត់បក្សដិវត្តន៍ចោទថាខ្មាំងបក្សដិវត្តន៍ ហើយអាចចាប់បានដោយមិនមានការសំរេចពីថ្នាក់លើ តាមខ្សែបណ្តោយអី?

**ម៉ីត:** គេពិភាក្សាគ្នាហើយៗ គេព្រមគ្នាហើយ ។

**ស៊ីវ:** បានសេចក្តីថាតាមពិតទៅអង្គភាពស-២១ ឬក៏បុគ្គលឌុចនិងមានស្នើរទៅថ្នាក់លើរបស់គេដើម្បីមានការចាប់ មិញគេថាគេមានខ្មាំងមួយនៅក្នុងដៃហើយ ហើយគេសួរចំលើយ សួរចំលើយហើយឈ្មោះកនិងឆ្លើយដាក់ខ-គអីទាំងប៉ុន្មានហ្នឹង ហើយបញ្ជីឈ្មោះហ្នឹងស-២១អាចនិងបញ្ជូនទៅថ្នាក់លើរបស់គេ ដើម្បីឲ្យថ្នាក់លើរបស់គេសំរេច សំរេចហើយបានគេបញ្ជារមកកន្លែងស-២១វិញថាឲ្យទៅចាប់ ហើយឲ្យមេភូមិភាគ ឬមេតំបន់និងចាប់ឲ្យហើយដើម្បីប្រគល់ទៅឲ្យពួកស-២១និងមិនមែនទៅចាប់ទេគឺមកទទួល ទទួលពីភូមិភាគមកដើម្បីកស-២១ចាប់ផ្តើមសួរចំលើយមួយដងទៀត?

**ម៉ីត:** អានិងវាអីចឹងទេវាបន្តគ្នាវាមិនអត្តនោមត្តបោះសន្ទូចរំលងភ្នំបានទេ ។

**សុជា:** ហើយអាឡានដែលទៅដឹកអ្នកទោសមកនិងឡានគេបិទជិតហើយ ដាក់ផ្លាកលេខដាក់ផ្លាកសញ្ញាអីម៉េច?

**ម៉ែត:** ទេដូចជាគ្មានលេខគ្មានអីទេ កាលនិងដូចជាអត់មានលេខដូចឡានយើងឥឡូវ មានផ្លាកលេខមានពន្ធមានអីឯណា ។

**សុជា:** អត់ទេដូចដាក់ថាមន្ទីរស-២១អី?

**ម៉ែត:** អត់ទេអត់មាដាក់ទេ តែដាក់លែងទំនង ។

**សុជា:** តែឡានបើចេញទៅក្រៅគេស្គាល់ គេដឹងថាមកចាប់អ្នកទោស?

**ម៉ែត:** ឡានតែចេញគេស្គាល់ហើយ តែទៅកន្លែងនិងមួយសារហើយចេញមកវិញគេថាបាត់អ្នកនេះ តែឃើញមកមួយសារទៀតអ្នកនៅនិងភ័យហើយ ព្រោះអីឡានវាឃុំបេត្របូលគ្រាន់តែទាញទំលាក់មក គេអាចដឹងថាឡាននិងវាមានសកម្មភាពថាបាត់អ្នកនេះ លើកក្រោយមកទៀតភ័យហើយ ។

**សុជា:** អានិងបើតាមខ្ញុំដឹងពីអ្នកដែលខ្ញុំសម្ភាសន៍ពីមុនៗមក វាមានច្រើនដូចអ្នកនៅខាងនិរតី នៅនិរតីវាមានមន្ទីរមួយនៅម្ខាងស្ពានច្បាអំពៅ កាលណាឆ្លងទៅខាងណោះស្ពានច្បារអំពៅទៅពួកបូព៌ា ហើយនៅកន្លែងនិងមានមន្ទីរពេទ្យមានអីនៅច្បារអំពៅហ្នឹង ហើយមានឡានអីនិងទៅចាប់អ្នកនៅមន្ទីរពេទ្យ នៅខាងបូព៌ានិងយកមកហើយអ្នកខ្លះទៀតកំបុងធ្វើការនៅព្រៃសព្រៃអីអីចឹង កំពុងតែសួងតែអីអីចឹងគេទៅហៅ ឡាននិងគេឈប់ចាំនៅនិងភ្លឺគេជញ្ជូនដាក់ឡាននិងយកទៅ?

**ម៉ែត:** អានិងបើនិយាយទៅសុទ្ធតែចំលើយចេញពីនេះទៅហើយបានគេទៅយក ទាល់តែចំលើយចេញមួយមកដូចថាមេមួយគេយកហើយណា នៅស្រុកកោះធំនេះឥឡូវគេចាប់បានមេណា ទៅដល់គេសួរមេនិងហើយអានិងតាមខ្ញុំយល់ទេណា ខ្ញុំមិនមែនជាអ្នកសួរចំលើយទេ តែអានេះតាមខ្ញុំយល់ គេយកមេនិងមួយទៅគេចាប់ផ្តើមសួរគេសួរថាមានអាណាខ្លះ ហ៊ុអានេះក៏ចូលបក្សគេអានេះក៏ចូកបក្សគេ អីចឹងគេស្រាវមកហើយយកមកហើយតាមថ្នាក់ហើយអានិងវាអីចឹងទេ តាមខ្ញុំយល់ខ្ញុំមិនមែនជាអ្នកសួរចំលើយទេតែខ្ញុំអាចយល់ថាលក្ខណៈអាកន្លែងគេចាប់ៗមកនិងវាអីចឹងទេ ។

**ស៊ីវ:** ឥឡូវខ្ញុំសូមសួរពីសភាពការណ៍ផ្ទៃក្នុងនៅអង្គភាពស-២១និងតែម្តង ហើយចង់និយាយពីការចាប់កម្មាភិបាលចាប់យុទ្ធជន ដែលនៅក្រោមក្របខ័ណ្ឌរបស់ស-២១និងតែម្តង បើតាមលោកពូមានប្រសាសន៍ទាំងប៉ុន្មានទាំងសម្ភាសន៍លើកមុន ទាំងនៅក្នុងថ្ងៃនេះផងខ្ញុំយល់

ឃើញថាវាអាចនិងមានការចាប់ផ្ដើមក្នុងខ្លួនឯងនិង៤យ៉ាង ចាប់ខ្ញុំរៀបរាប់ៈទី១ ដោយសារមានចាប់អ្នកណាម្នាក់ហើយស-២១ខ្លួនឯងនិងសួរចំលើយ សួរចំលើយហើយមនុស្សនិងឆ្លើយដាក់ឈ្មោះកឈ្មោះខអីចឹងទៅ ហើយគេចាប់មនុស្សទាំងអស់គ្នានិងទៅ បន្តគ្នាតាមខ្សែរយះអានិងទី១ ទី២មានអ្នកធ្វើខុស ធ្វើខុសហើយមានអ្នកពិនិត្យប្រវត្តិរូប ពិនិត្យប្រវត្តិរូបហើយគេឃើញថាមានសមាសភាពមិនល្អអានិងគេចាប់អានិងមួយទៀត ទី៣គឺថាប្រជុំជីវភាពមានការធ្វើទិទានស៊ុយទិទានទៅវិញទៅមកនិង ហើយបើយាយភាសាសាមញ្ញគឺថាចោទប្រកាន់គ្នាទៅវិញទៅមកអានិងទី៣ ទី៤និងដល់ធ្វើប្រវត្តិរូបហើយឃើញថាមានសមាសភាពមិនល្អដូចជាវណ្ណៈភាពដើមមិនល្អ ឬក៏ជាប់និងនាការឬក៏ជាជនជាតិជាគេញជានេះជានោះ អីចឹងខ្ញុំចង់សួរថាបើតាមដែលលោកពូដឹងលោកពូយល់ តើរឿងមានទាំង៤យ៉ាងដូចខ្ញុំនិយាយមិញនិងណា?

**ម៉ៅត:** មាន មានមិនអត់ទេអាហ្នឹង ។

**សុជាៈ** អីចឹងចាប់ហើយសួរចំលើយ ហើយចាប់គ១គ្នាផ្ដើមក្នុងអង្គភាពខ្លួនឯងនិងណា?

**ម៉ៅត:** បា!មាន ។

**សុជាៈ** ខ្ញុំសួរបញ្ជាក់ថាអារឿងផ្ដើមក្នុងស-២១និង អារឿងនិងក៏ត្រូវឆ្លងថ្នាក់លើទៀតដែរ ឬក៏ខុចជាអ្នកសំរេចខ្លួនឯងបាន បើចង់ចាប់កម្មាភិបាលខ្លួនឯង ទាល់តែថ្នាក់លើគេអនុញ្ញាតឲ្យចាប់កម្មាភិបាលខ្លួនឯង ឬក៏គាត់មានសិទ្ធសំរេចដោយខ្លួនឯង?

**ម៉ៅត:** ទេខ្ញុំវាអត់បានដឹងដែរ និយាយរួមទៅឌុចនិងគាត់ច្រើនលេងផ្លូវកាត់ដែរ ច្រើនផ្លូវកាត់ទេអាឌុចវាមិនសូវជាប៉ុន្មានទេ ទាល់តែអ្នកធំៗធ្លាប់ធ្វើការជាមួយអ្នកធំនិងហ្នឹងបានវាទំនាក់ទំនងទៅ បើថាដូចជាអាចក់អាប៉ែមអាតូចអាតាចនេះវាសំរេចហើយ ផ្លូវកាត់ដែរហ្នឹង ។

**សុជាៈ** ដូចគាត់ចង់និយាយថាអ្នកដែលធ្វើសន្តិសុខនិងក្រោយមក ត្រូវបានគេចាប់ដាក់នៅក្នុងគុកនិងដែរ នៅនិងមានអីចឹងដែរ?

**ម៉ៅត:** មាន ខ្ញុំក៏ដឹងដែរអារឿងដែលគេចាប់និងជួនកាលខុទាហរណ៍ថា ឥឡូវដូចថាឲ្យចយនិងរួចនៅក្នុងគុកទួលស្លែងនិងណា ហើយចយនិងរួចមកដល់សព្វថ្ងៃតែឥឡូវចយនិងគាត់ស្លាប់បាត់ហើយផ្ទះនៅកំពង់កុងនិងដែរ ហើយរួចនិងចយនិងរួចទៅដល់ស្រុកយួន ប៉ុនគេចាប់អាហ៊ីនិងហើយ១អានិងឈ្មោះអាហ៊ី គេចាប់អាហ៊ីនិងអាហ៊ីគេសួរចំលើយវាថាអ្នកនេះអ្នក

នោះឲ្យប្រលែង ឬមួយក៏ប្រហែលអ៊ីចឹងទៅណា ហើយគេចាប់អាហ៊ឹងនិងទៅណា ហើយមកលេងអាគ្នាឯងដែលកំពុងយាមជាមួយគ្នាហ្នឹង ចាប់បន្តគ្នារហូតដូចសម្លរកំពីសអាយូកអស់ហើយពួកខ្ញុំដែលចូលរៀននៅសាលាបច្ចេកទេសទាំងប៉ុន្មាន ប្រហែលជា៣០នាក់និងហើយសល់ប៉ុន្មាននាក់និងដូចថាអាយុវាមិនអស់ នៅតែប៉ុន្មាននាក់និងក្រៅពីនិងអស់ហើយរលីងតិលហ្មង ។

**សុជាៈ** ចុះអារឿងថាជួលកាលប្រជុំជីវទស្សន៍និងកសាងគ្នាទៅវិញទៅមក ធ្វើទិទានស្មាយទិទានគ្នាជួនកាលមានចាក់គ្នាទៅវិញទៅមករហូតដល់មានការចាប់ទេ?

**ម៉ើតៈ** អានិងបើនិយាយទៅមកពីនិយមបក្សពួក ដូចថាកនិងទិទានឈ្មោះខនិងខ្លាំងខនិងដូចជាជាប់ខ្សែរយៈត្រូវជាប្អូនអាមេនិង អានេះទិទានខ្លាំងទៅវាចូលសំនុំរឿងខ្លាំងទៅ អានោះក៏វាចាបផ្តើមចោទគេមកចាប់អានេះក៏មានដែរ អានិងវាអ៊ីចឹងវាស៊ីតាមខ្សែវាដែរ ។

**សុជាៈ** ក៏ប៉ុន្តែវាមកពីគ្នាឯងនិងដែរ មិនមែនមកពីថ្នាក់លើចាត់ឲ្យធ្វើទេ មកពីគ្នាឯងនិងហ្មង?

**ម៉ើតៈ** មិនមែនទេ ឈ្មោះគ្នាអ៊ីទិទានគ្នាអាខ្វះវាយកមុខយកម៉ាត់ វាខំធ្វើការឲ្យស្អាត់ក្រែងលគេឲ្យឡើងអ៊ីចឹងទៅ ទិទានអាគ្នានេះអត់ដឹងអីថាគ្នានេះយាមឯក់ សួរចំលើយឯក់អីអ៊ីចឹងទៅឬមួយយាមដេកដើរគ្មានវិន័យអ៊ីចឹងទៅ ចុះធម្មតាអ្នកយាមមួយយប់ទើសភ្លឺដូរគ្នាតែម្តងហើយធម្មតាចេះតែឯក់ងុយហើយ ហើយគេមកទាន់ចេះតែទិទានហើយគេយកទៅកសាងទៅ ជួនកាលយើងនិងវាមានធ្វើខុសហើយគេមកទាន់ហើយ យើងនិងដាក់ខ្លួនឲ្យគេកសាងទៅអានិងវាមានតែអ៊ីចឹង ។

**ស៊ីវៈ** ប៉ុន្តែថ្នាក់លើគេមានស្រាវជ្រាវឲ្យរកខ្មាំងបង្កប់ផ្ទៃក្នុងនៅក្នុងអង្គភាពខ្លួនឯងដែរទេ?

**ម៉ើតៈ** មាន ។

**ស៊ីវៈ** អ៊ីចឹងប្រជុំគ្នាឯងមានចោទគ្នាទៅវិញទៅមកនិងយកឡេះថាយើងជាខ្មាំងបង្កប់ផ្ទៃក្នុង បានគេចាប់បាន?

**ម៉ើតៈ** កន្លែងនិងមិនដឹងជាគេឲ្យម៉េចអីម៉េច មិនមែនថាត្រឹមតែប៉ុណ្ណឹងទេជួនកាលនិងវាចាប់មួយម្នាក់និងទៅហើយវាចេះតែឆ្លើយទៅ ចុះធម្មតាឈឺវាចេះតែឆ្លើយហើយដាក់ដាំងអូយអាណាសុខចិត្តនៅអ៊ីចឹង វាចេះតែឆ្លើយមកថាមិត្តនេះឲ្យខ្ញុំធ្វើសកម្មភាពចេះៗមួយ ហើយអាអ្នកនោះចេះតែកត់ចូលទៅក្នុងឯកសារទៅ ហើយសួរទៀតទៅមកដដែលៗហើយចាប់

អានោះមួយទៅហើយអានេះគ្រាន់តែខុសតែបន្តិចនិងចាប់ទៅទៀតហើយ អានិងវាអ៊ីចឹង ហើយសុទ្ធតែរឿងចោទដាក់គ្នាតែរហូត បើវានិយាយថាខ្មាំងទាំងអស់និងវាងាប់ទាល់តែអស់ ដល់អ៊ីចឹងអាខុចនិងវាចេះតែអត្តនោមត្តហើយ អានិងដូចថាព្រាយចូលនៅក្នុងខ្លួនវាអាហ្នឹង ។

**ស៊ីវៈ** ឃើញសម្ភាសន៍លើកមុននិងមាននិយាយពីកម្មភិបាលនោស-២១ ប្រហែលជាយុទ្ធជន១នាក់ដែលមានឈ្មោះស្មាន?

**ម៉ៅតៈ** ស្មានហ្អេ!

**ស៊ីវៈ** ស្មាននិងជាជនជាតិចាម?

**ម៉ៅតៈ** ស្មាននិងវាមុនដំបូងវាជាកងការពារ ដល់ហើយគេដកពីកងការពារឲ្យសួរចំលើយ ។

**ស៊ីវៈ** ហើយជាជនជាតិអីគេ?

**ម៉ៅតៈ** ជាជនជាតិចាម ចាមនិងវាមានពីរមានអាម៉ាននៅកោះក្របី ។

**សុជាៈ** ចុះសុះស្មានមួយនៅកោះធំ?

**ម៉ៅតៈ** ស្មាននៅកោះធំនៅចាមក្រោមមួយ ។

**សុជាៈ** អានិងគាត់ធ្វើអីគេ?

**ម៉ៅតៈ** អានិងមុនដំបូងជានិរសាអ៊ិនណាត ដល់ហើយគេដកអ៊ិនណាតទៅអង្គការសហប្រជាជាតិអីឯណា ដល់បានវានិងគេត្រូវយកធ្វើកងការពារ ។

**សុជាៈ** នៅស-២១ហ្នឹង?

**ម៉ៅតៈ** បាធ្វើពីកងការពារមកគេឲ្យវាមកសួរចំលើយ និងអាម៉ាននៅក្រោមនេះ ។

**សុជាៈ** នៅចាមក្រោមខ្ញុំសម្ភាសន៍ដែរ ហើយចុះថាម៉ានមួយទៀតនោះដែលថាចាប់ខ្លួននោះ?

**ម៉ៅតៈ** អាម៉ាននោះជាម៉ានសួរចំលើយទេ អាម៉ាននេះនៅកោះក្របីកោះអន្ទង់ចិនអីមិនដឹងទេ ។

**សុជាៈ** អានិងគាត់ធ្វើអីគេ?

**ម៉ៅតៈ** អានិងជាអ្នកសួរចំលើយ ។

**សុជាៈ** ចុះម៉ាននេះសួរចំលើយដែរ?

**ម៉ៅតៈ** អានេះយាមផងសួរចំលើយផង វាមានពីរផ្នែក ។

**ស៊ីវៈ** ហើយអាបញ្ហាដែលគេជាជនជាតិចាមនិង អារឿងដែលគេជាជនជាតិចាមនិងគេចាត់ទុកថាមានសមាសភាពមិនល្អដែរឬក៏យ៉ាងម៉េច?

**ម៉ើតៈ** ខ្ញុំអត់ដឹងអានិងបើតាមមើលគេមិនគិតទេ គេគិតតែអ្នកណាដែលធ្វើការល្អ អានិងអីចឹងហ្នឹងឲ្យតែអ្នកណាធ្វើការល្អអានិងបោះហើយ ។

**ស៊ីវៈ** អីចឹងអាបញ្ហាដែលថាមានប្រកាន់ពូជសាសន៍មានប្រកាន់ជនជាតិចាមអី បើនិយាយទៅដូចជាអត់មានទេ នៅកន្លែងលោកពូហាក់ដូចជាអត់មានគំនិតនិងទេ?

**ម៉ើតៈ** អត់មានទេ ប៉ុន្តែបើជាប់ជនជាតិវៀតណាមអត់នៅទេ ដកចេញហើយបើថាដូចជណជាតិចាមដូនកាលគេធ្វើការល្អទៅវា កាលនៅមួយជំនាន់និងវាពិបាកដឹង ដូចថាខ្ញុំទើបតែយល់នៅនិងយើងសព្វថ្ងៃនេះទេ បើពីមុនៗអត់មានទេ ។

**ស៊ីវៈ** ហើយយើងទាំងអស់គ្នាគឺជាអន្តែបនៅក្នុងអណ្តូងទាំងអស់គ្នាតើ?

**ម៉ើតៈ** បា!

**ស៊ីវៈ** ធម្មតាយើងដើរសួរគេទាំងអស់ ដើម្បីប្រមូលវាទាំងអស់យកមកសរុបថាជាទូទៅថាវានិងយ៉ាងម៉េច អីចឹងយើងនិយាយជាក់ស្តែងតែនៅក្នុងអគ្គភាពលោកពូមួយទេណា មិញវាហាក់ដូចជាចង់និយាយថាកន្លែងហ្នឹង បើតាមតែលោកពូសង្កេតឃើញវាហាក់ដូចជាគ្មានអាដែងគំនិតប្រកាន់ពូជសាសន៍ចាមអីទេ បើធ្វើការល្អក៏គេនិបល្មីវវល់ថាចាមឬជាចិន លើកលែងតែយួនមួយ?

**ម៉ើតៈ** វាសំខាន់គឺរឿងធ្វើការល្អនិងហ្នឹង ហើយគ្រាន់តែពូជសាសន៍អីដូចយួនអីនិងគេប្រកាន់បន្តិចហើយ ។

**ស៊ីវៈ** តែចាមចិនអីអត់មានប្រកាន់ទេ?

**ម៉ើតៈ** អត់ទេ តែបើនិយាយរួមគឺថាឲ្យតែល្អហ្នឹង ។

**សុជាៈ** តែពូក្រោយមកដូចសុះស្មានេះត្រូវគេដកចេញពីកងការពារដែរតើ ពីខាងស-២១និងដែរតើ ខ្ញុំលឺគេសួរគាត់ណា គាត់ថាមុននៅនិងដែរតែក្រោយមកត្រូវគេដកមកឲ្យនៅខាងសេដ្ឋកិច្ចវិញ គាត់មករកត្រីអីនៅមុខវាំងមុខអី ដល់ពេលរកហើយអីចឹងគាត់ដឹងដំណឹងថាឪពុកគាត់ត្រូវគេយកទៅសំលាប់ ដោយសារតែរឿងស្បែកជើងមួយដែលភ្លេចនៅលើរទេះអីចឹង ថាគាត់និងជាប់និងកម្មសិទ្ធគេហើយអីចឹង គេយកឪពុកទៅសំលាប់ សុះស្មាន

និងដឹងរឿងអីចឹងក៏សុំគេទៅផ្ទះតែគេមិនឲ្យមក សុះស្មាននិងក៏ជិះកាណូតដែលរកត្រីនៅមុខវាំងនិងមកយើងនេះ តែពេលនិងគេតាមចាប់ស្មាននិងពីរបីដង អញ្ចឹងបានន័យថាសុះស្មាននិងមានរឿងជាប់និងខ្លួនហើយបានជាគេទំលាក់ពីស-២១មកហ្នឹង?

**ម៉ែត:** អត់ដឹងដែរ ។

**ស៊ីវ:** ឬក៏គាត់និយាយផ្សេងទេ គាត់នៅស-២១និងរហូតទេ?

**ម៉ែត:** គាត់និងនៅនិងរហូត តែនៅពេលរយះនិងវាបាត់ច្រើនតង់ច្រើនថ្នាក់ពេក ជូនកាលដកទៅឯណោះជូនកាលដកទៅឯណោះបាត់ទៅ ពូក៏អត់បានក្តាប់រឿងគេដុំដែរ សព្វថ្ងៃនេះយូងតែអាត្មាយូងតែខ្លួនឯងធ្វើម៉េចកុំឲ្យតែគេចោទកុំឲ្យតែគេថា បើគេថាឲ្យរែកទៅស្រោចគុម្ពស្ពៃនិងបេះតែធ្វើទៅ ហៅមកវិញអត់មកទេសុខចិត្តអត់បាយអត់អីណោះ ។

**សុជា:** ចុះសុះស្មានដែលថានៅកោះអន្លង់ចិនឬកោះក្របីអីនោះតើគេយកទៅសម្លាប់ឬក៏បាត់ខ្លួន.?

**ម៉ែត:** មិនដឹងបើនិយាយរួម បើសួរខ្ញុំគឺមានតែសួរទេព្រោះអីខ្ញុំបានដឹងពីរឿងអ្នកដែលខ្ញុំសួរ ចំលើយសួរអីនិងវាអាចដឹងព្រោះអីវានៅក្នុងរង្វង់វានិងវាអាចដឹងណា ចំណែកខ្ញុំជាកងការពារនិងសូម្បីតែនៅក្នុងអាគារខ្ញុំនិងក៏ខ្ញុំអត់ដែលចូលផង ។

**ស៊ីវ:** អញ្ចឹងនៅខាងក្រៅ?

**ម៉ែត:** បា!ខ្ញុំនៅខាងក្រៅ នៅនិងដូចថាយាមអ្នក ដូចថាយើងអត់ស្គាល់ឈ្មោះទេទើបតែឥឡូវដឹងថាដូចឌុចអីហ៊ូនឹមអីចឹងទៅ ឬមួយអ្នកណាៗមួយអ្នកធំអីនិងគ្រាន់តែអត់ស្គាល់ឈ្មោះអត់ស្គាល់មុខអីទេណា គ្រាន់តែគេថាយាមនៅមួយដុំនិងសុទ្ធតែអ្នកធំៗដូចហ៊ូនឹម ហ៊ូ យន់អីណោះ ហើយអ្នកណាស្គាល់បើអត់ស្គាល់ផង គេចាប់មកពីណាពីណីទេអត់ដឹងដល់ហើយគេថាមិត្តឯងឡើងទៅយាម ។

**ស៊ីវ:** ចំនុចនិងខ្ញុំសូមសួរពូដូចឆោតមួយណាលោកពូ ក្នុងពេលនោះខ្ញុំនិយាយពីឆ្នាំ៧៧-៧៨អីនិងណា ពូធ្លាប់ឃើញពួកនិងគេយកមកថ្នាក់ភូមិភាគក៏មាន ថ្នាក់តំបន់ក៏មាន ថ្នាក់កងពលអីក៏មាន ហើយគេថាពួកនិងសុទ្ធតែក្បត់ ក្បត់អីចូលយួនចូលអីចូលជាសេអ៊ីអា ចូលជាកាសេបេទាំងប៉ុន្មាននិងណា ពេលនោះលោកពូជឿទេថាពួកនិងចូលសេអ៊ីអាចូលយួន ចូលកាសេបេនិងមែនឬក៏យ៉ាងម៉េចដែរ?

**ម៉ែត:** ខ្ញុំរឿងនិងបើពីមុនខ្ញុំអត់មានយល់ទេ ។

**ស៊ីវៈ** តែនៅក្នុងពេលនោះ?

**ម៉ឺតៈ** អត់យល់ អត់យល់អីសោះ ។

**ស៊ីវៈ** អត់យល់និងបានសេចក្តីថាជឿដែរឬក៏យ៉ាងម៉េច?

**ម៉ឺតៈ** អត់ជឿទេលោកគ្រូ ។

**សុជាៈ** អត់គាត់ចង់ថាមនុស្សម្នាក់ដែលគេចោទថា ជាប់ខ្សែជាសេអ៊ីអាដែលគេចាប់យកទៅហ្នឹងណា តើគាត់ជាប់ខ្សែអ៊ីអាមែនឬក៏មិនមែន ហើយពូមានអារម្មណ៍ថាជឿតាមការដែលគេចោទនិងដែរទេ?

**ម៉ឺតៈ** អានិងខ្ញុំវាមានអារម្មណ៍មួយថាជឿ ជឿថាកាលនិងគាត់ធ្វើសង្គ្រាមពីមុនគាត់មិនត្រូវជាមួយយួន ដល់តែគាត់រំដោះហើយវៃយួនវិញអានិងវាពិបាកដែរវៃគ្នាទៅវិញទៅមក អីចឹងពីមុនមកវាមានជាប់សេអ៊ីអា ចូលជាមួយទ័ពពួកយៀកកុងអីទៅណា អានិងវាអីចឹងហើយពីមុនមកនោះ អានិងខ្ញុំអាចយល់មែនហើយដល់តែពេលនិងជឿតាមគេ ហើយដល់ពេលខ្មាតពីយៀកកុងម៉ោមក មកចូលជាមួយខ្មែរវិញមកដល់តែពេលដំណាក់កាលនិងគេចោទវិញហើយ យើងចូលនោះអីហើយៗអីចឹង ហើយយើងមកចូលរួមចំណែកវៃលន់ណុលវៃអីនៅនេះទៀត ខ្ញុំអាចយល់អីចឹងដែរខ្ញុំអាចយល់ ។

**ស៊ីវៈ** អីចឹងទើបតែក្រោយ៧៩ហើយពេលបែកហើយ ទើបចាប់ផ្តើមថារឿងនិងប្រហែលជារឿងមិនមែនជារឿងមិនពិត អារឿងដែលចោទពួកនេះថាចូលនេះចូលនោះនិងណា?

**ម៉ឺតៈ** រឿងបើគិតទៅខ្ញុំថាដូចអត់ពិតទេ ។

**សុជាៈ** តែនៅក្នុងពេលនោះ?

**ម៉ឺតៈ** ពេលនោះជឿក៏ជឿតាមតែគេទេ ហើយខ្ញុំគ្រាន់តែពិនិត្យមើលខ្ញុំថាដូចបងខ្ញុំអីគ្នាចូលទៅស្រុកវគ្នាដែរចូលដូចខ្ញុំដែរហើយមានសេអ៊ីអា ពីណាមកបើចូលជាមួយគ្នាបើអត់ដឹង ដឹងតែធ្វើទ័ពគេឲ្យវៃជាមួយខ្មាំងចេះតែវៃទៅ ហើយដល់តែបច្ចុប្បន្នអាឆ្នាំ៧៨អីនេះ យកគ្នាមកវៃចោលនេះ ។

**សុជាៈ** ពួកបងពូ គាឈុនគាអីហ្នឹង?

**ម៉ឺតៈ** បា!គាឈុនគាអីនិងហើយគាត់ចូលសេអ៊ីអាជាមួយពីណា ។

**សុជាៈ** ពូឈ្មោះអីគេ?

**ម៉ឺត:** ឈ្មោះសោម ម៉េង ។

**សុជា:** គាត់នៅអង្គភាពស-២១ជាមួយពូដែរ?

**ម៉ឺត:** អត់ទេអត់មាននៅទេ គាត់នៅទ័ពហើយគាត់នៅធ្វើទាហាននៅខេត្តកំពង់ឆ្នាំង ។

**សុជា:** ហើយដល់ពេលដែលគេចាប់បញ្ចូល?

**ម៉ឺត:** ពេលដែលគេចាប់បញ្ចូលទៅស-២១និងខ្ញុំក៏អត់ដឹងដែរ គេអត់ឲ្យខ្ញុំដឹងទេបើខ្ញុំដឹងខ្លាចខ្ញុំធ្វើសកម្មភាព ណាមួយនិងមានសតិអារម្មណ៍មួយដើម្បីរត់ស៊ូ អ៊ីចឹងគេអត់ឲ្យខ្ញុំដឹងទេ ដល់មកក្រោយនេះបានបងហ៊ុយទេបានគេឲ្យដឹង ។

**សុជា:** ហ៊ុយតូចហ្នឹង?

**ម៉ឺត:** បា!ហ៊ុយតូចនេះគេថា ម៉េតឯងនៅឲ្យស្ងៀមទប់ជំហរមែនទែនគេកំពង់តាមដានម៉េតឯងរឿងបងម៉េតឯងចូលអីនិងហើយគេចាប់មកនិងណា ខ្ញុំក៏នឹកឃើញថាវាឈ្លួលហើយប៉ុនវាមិនដឹងជាធ្វើអីកើតយើងតែម្នាក់ឯង ហើយគេវាទាំងហ្វូងយើងធ្វើមិនកើត អ៊ីចឹងសុខចិត្តឲ្យស្លាប់តែមួយនាក់ឲ្យរស់ម្នាក់ចុះ ហើយខ្ញុំក៏និយាយជាមួយបងហ៊ុយដែរធ្វើម៉េចឥឡូវបើអ៊ីចឹង ហើយគ្រាន់តែរឿងខ្ញុំធម្មតាខ្ញុំប្រយ័ត្នបន្តិចហើយ កុំហៅខ្ញុំទៅប្រជុំទៅកន្លែងបងអីដឹងតែខ្ញុំអត់ទៅហើយ ខ្ញុំសុខចិត្តងាប់ក្រៅតែចូលគុកឈឺហើយងាប់ដដែល។ ខ្ញុំនឹងឃើញអ៊ីចឹង ប៉ុនមិនហ៊ាននិយាយប្រាប់ហ៊ុយទៀត ប៉ុន្តែគេ។នឹកឃើញអាណិតខ្ញុំណា ឃើញបងចូលកន្លែងនិងហើយ ខ្លួនឯងដឹងហើយឈឺហើយយើងធ្វើតាមទៀតងាប់ដដែល អ៊ីចឹងគេអាណិតគេជួយលាក់នឹកឃើញថាគ្នាវាស្លូតគ្នាវាត្រង់ ហើយដឹងតែពីយាមទេហើយចុះកាលនោះខ្ញុំវាមិនទាន់ចេះហូបចេះចុកចេះអាដែងហ៊ីហាឯណា ដឹងដែរដល់គេហៅទៅបាយក៏ទៅបាយទៅ គេហៅទៅដូរយាមចេះតែយាមទៅ កាលនោះមិនមែនដូចយើងសព្វថ្ងៃចេះមាត់ចេះសំដីឯណា ពីមុននិងនោះចំហើយដល់ឥឡូវសង្គមវាមានសេរីភាពទៅវាចេះតែបានសំដីអីខ្លះ ។

**ស្មីវ:** ប៉ុន្តែករណីរបស់លោកពូក្រោយមកមិនគេបញ្ជូនទៅព្រៃសមិនអ៊ីចឹង ហើយអារឿងនិងវាហាក់ដូចជាចូលទៅអ៊ីទី១ដែលខ្ញុំសួរមិញហ្នឹង ជារឿងផ្ទៃក្នុងអង្គភាពស-២១តែម្តងមានដូចថាបងម៉េងនិងត្រូវគេចាប់ ហើយឆ្លើយដាក់លោកនៅក្នុងបញ្ជីរសារភាពរបស់គេ ឬក៏អត់ដឹងថាគាត់ឆ្លើយដាក់ឬមិនឆ្លើយដាក់?

**ម៉ឺត:** អត់ដឹងផង រឿងនិងខ្ញុំអត់ដឹងផង ។

**ស៊ីវ:** ពីព្រោះមានបើឆ្លើយដាក់និងពួកខាងលើនិងគេថាមិនចាំកម្មេចទេ គេបញ្ជូនទៅអប់រំគេមានសិទ្ធសំរេចថាតើត្រូវតែយកទៅសំលាប់និងថាតើត្រូវយកទៅអប់រំ ។

**ម៉ឺត:** បងខ្ញុំហ្នឹងហ្អេ! ។

**សុជា:** អត់ទេលោកពូខ្លួនឯង!

**ម៉ឺត:** ខ្ញុំកាលនិងដែលចេញរឿងហេតុបងខ្ញុំមកហ្នឹង អានិងខ្ញុំទៅឯណោះគេគ្រាន់តែយកទៅអប់រំហើយគេឲ្យយើងដូចថាធ្វើស្រូវធ្វើអីទៅណា ។

**ស៊ីវ:** ខ្ញុំចង់ដឹងថាតើអ្នកណាមិនសំរេចថាមិនយកលោកពូទៅសម្លាប់ទេ ហើយលោកពូទៅអប់រំវិញ?

**ម៉ឺត:** បើនិយាយទៅហ៊ុយទេ ។

**សុជា:** ហ៊ុយតូចហ្នឹង!

**ម៉ឺត:** បា!ហ៊ុយតូចនិងគេថាអីចេះទៅ គេនិយាយជាមួយផល ៗ និងគេមកយកឲ្យខ្ញុំជិះឡានទៅ ខ្ញុំកាលនិងខ្ញុំនឹកឃើញថា.......ហ៊ុយនិងក៏មុខស្លេកដែរតែខ្ញុំទៅហ៊ុយនិងក៏មិនដឹងម៉េចដែរ តែដល់ចេះទៅមិត្តព្រលឹមឡើងម៉ោង៨ហ្នឹង មិត្តឯងរៀបចំវាល់ឡូរៀបចំឥវ៉ាន់អីទៅណា ទៅស្រែទៅហើយទៅស្រែនិងវាមានច្រើនប្រភេទទៀត ទៅធ្វើស្រែនិងមិនដឹងជាគេយកទៅធ្វើស្រែឬក៏គេយកទៅវៃចោលទេ កន្លែងនិងវាមានពីរកន្លែងណានោកន្លែងហ្នឹង អារឿងទៅធ្វើស្រែនិងវាដឹងតែទៅធ្វើហើយ ប៉ុនវាមានមួយចំនុចទៀតតែមិនដឹងជាគេយកទៅវៃចោល ព្រោះវាដូចថាវាមានរឿងចំលើយអីផង វាអត់មានថាជាសេអ៊ីអាវាអត់មានជាប់ជាមួយអីទេវាមានតែជាមួយផុងហ្នឹង ប្រវត្តិរូបមានបងធ្វើជាទាហានលន់ នល់និងមានបងដែលជាប់គុកនិងទេ ។

**ស៊ីវ:** អានិងធូន់ដែរមានឈ្មោះជាប់និន្នាការពីរជងហើយ!

**ម៉ឺត:** ពីរជងបីជងតាំងពីគេឲ្យរួចមកនោះ ។

**ស៊ីវ:** រឿងកាលនោកន្លែងអ្នកទោសក៏មានហើយ នៅដាំដេងនិងមួយ ទី២មានបងម្នាក់ធ្វើជាទាហានលន់ នល់ និងទី៣មានបងម្នាក់ទៀតគេចោទថាក្បត់ ប៉ុន្តែហ៊ុយនិងនៅការពារបានហ៊ុយតូចនិងគាត់នៅការពារបាន?

**ម៉ើត៖** គាត់នៅជួយសម្រួលបាន នឹកឃើញថាគេធ្លាប់ឃើញប្រវត្តយើង មិនដឹងជាប្រវត្តយើងម៉េចទេតែយើងវាអត់ចេះមាត់អត់ចេះក ហើយស្លូតគេឲ្យធ្វើអីក៏ធ្វើហ្នឹង ប៉ុនតែបើគេឲ្យយាមគឺដឹងតែយាមហើយ ។

**សុជា៖** តែហ៊ុយនិងបើដឹងថាគេដឹងរឿងជួយលាក់ពូហ្នឹង ដឹងដល់ខុចដល់អីហ្នឹងតើគាត់និងមានផលវិបាកអីដល់ហ៊ុយនិងវិញទេ ឬក៏ហ៊ុយនិងគិតថាបើសិនជាដឹងរឿងនិងដល់ខុចដល់អីនិងតើគាត់មានដឹងថាមានផលវិបាកអីដល់ហ៊ុយនិងវិញទេ ឬក៏ហ៊ុយថាអត់មានបញ្ហាអីទេបើសិនជាខុចដឹង?

**ម៉ើត៖** បើខុចដឹងហ៊ុយនិងក៏មិនអាចធានាបានដែរបើខុចដឹង ប៉ុនអាបញ្ជីរនេះដូចថាបើនិយាយទៅវាច្រឡូកច្រឡំគ្នាណាបងវាអាចមានអីចឹងដែរ មិនមែនតែអន្ទុយឃ្លៀងទាំងអស់ឯណាខុចហើយណាមួយអាបងនិងក៏អត់ដឹងប្អូននៅនិងដែរ ហើយបើវាដឹងវិញវាគ្រាន់តែថាប្អូននៅនេះច្បាស់ជាទៅហើយ អានេះតែវាយកមកវាសួរហើយ ។

**សុជា៖** ហើយគេចោទគាត់ថាជាស្អី ជាខ្សែរយេះអីបានជាគេចាប់គាត់មកហ្នឹង?

**ម៉ើត៖** ពិនិត្យទៅគេថាវាចូលសេអ៊ីអា ។

**សុជា៖** ហើយគេចាប់ចេញពីណាមក?

**ម៉ើត៖** គេចាប់ចេញពីព្រលានយន្តហោះកំពង់ឆ្នាំងមក ។

**សុជា៖** គាត់ទៅកំពង់ឆ្នាំនិងគាត់នៅអង្គភាពណា?

**ម៉ើត៖** នៅអង្គភាព៧០៣ ។

**សុជា៖** ពេលនិងមានដឹងថាគេចាប់តាណាតហើយឬនៅ?

**ម៉ើត៖** ទេពេលនិងដូចជានៅក្រោយតាណាតទេ ។

**សុជា៖** អ៊ីចឹងបានន័យថាគេចាប់តាណាតហើយ?

**ម៉ើត៖** ហ្អេ!មិនដឹងជាមុនឬក្រោយតាណាតទេ ។

**សុជា៖** ឆ្នាំណាពូ?

**ម៉ើត៖** វានៅក្នុងឆ្នាំ៧៨ ។

**សុជា៖** ចុងឬក៏ដើម?

**ម៉ើត៖** និយាយទៅវាមិនចុងទេ វាជិតបែកដែរនិងគ្រាន់តែខ្ញុំទៅឯណោះនៅឯណោះក្តួង ។

**សុជាៈ** ចុះពេលដែលគេចាប់គាត់?

**ម៉ើតៈ** បានប៉ុន្មានខែទេ ។

**សុជាៈ** អាមុនគេចាប់គាត់ទៅដាក់នៅ៧០៣ទៅដាក់នៅព្រលានយន្តហោះហ្នឹង តើគាត់មានឋានៈត្រឹមណាដែរ?

**ម៉ើតៈ** អានេះបើនិយាយទៅគេអត់ចាប់ទេ គេគ្រាន់តែដូចជាគេចាត់តាំងឲ្យចូលអង្គភាពនិងទេណា ព្រោះអីវាពិការ វាពិការភ្នែកនេះពិការនេះផងហើយគេទៅកន្លែងអ្នកពិការហ្នឹង ធ្វើព្រលានយន្តហោះកំពង់ឆ្នាំង ហើយដល់តែហើយទៅវាមិនដឹងជាមានរឿងអីពីនោះមកវិញ ហើយវាអត់ដឹងរឿងដែរ ។

**សុជាៈ** ចុះក្រោយពីនិងមកពេលដែលពូទៅស្រែទៅអី ពូមានចាំថាទៅនៅខាងណានៅភ្នំពេញនិងដែលទៅស្រែហ្នឹង?

**ម៉ើតៈ** ទៅនៅនិងព្រៃសហ្នឹង ។

**សុជាៈ** ហើយក្រោយមកមានដឹងថាបងពូគេយកទៅកម្ទេចទេ?

**ម៉ើតៈ** ដឹងហ៊ុយអីគេនិយាយប្រាប់ ។

**ស៊ីវៈ** គេមានពាក្យឆ្លើយទេពីឈ្មោះ សោម ម៉េង ហើយខ្ញុំឆែកមើលហើយប្តីរបស់នាងដែលទៅជួបនៅនេះ គាត់មានពាក្យឆ្លើយទេ?

**ម៉ើតៈ** រូបថតខ្ញុំយកមកដែរ ប៊ិនម៉ែខ្ញុំគាត់យកទៅ រូបថតខ្ញុំយកពីទួលស្លែងកាលនោះគេចង់អីចេះហើយគេដាក់លេខ៨៨ កាលនោះតាប៉ាន់ឲ្យខ្ញុំដើរមើល ឲ្យមើលអីចឹងខ្ញុំមើលឃើញកាលនិងមិនដឹងជាស្លាប់អាយុប៉ុន្មានទេ រូបនិងខ្ញុំយកទៅពង្រីកហើយម៉ែខ្ញុំគាត់យកទៅ គាត់ចាស់ហើយបានគាត់យកអាយុ៨២-៨៣ហើយ ។

**ស៊ីវៈ** ប៉ុន្តែចុងក្រោយបំផុតនិងហ៊ុយនិងក៏ត្រូវចាប់ដែរ?

**ម៉ើតៈ** ទៀតទៅ ។

**ស៊ីវៈ** អត់ទេៗហ៊ុយតូចអត់ចាប់ទេ ហ៊ុយធំបានចាប់ ។

**សុជាៈ** ហ៊ុយតូចនៅរស់រាល់ថ្ងៃ?

**ម៉ើតៈ** ហ៊ុយនិងក៏មុខស្មេកដូចតែគ្នាដែរ ភ័យក្តុកក្តួលរកតែកន្លែងគេចមិនដឹងជាទៅឯណា តែហ៊ុយគេចបាត់បងប្អូននៅឯផ្ទះយកទៅទាំងអស់ សាកមើលបើមិនយកទាំងអស់ ។

សុជាៈ ចាំមើលពូ! នៅក្នុងប្រវត្តិរូបនេះគេដាក់ថាកន្លែងនេះថាវគ្គសិក្សារៀនសូត្រនិងណា អានេះខ្ញុំសួរបន្តពីលោកដែលមកសួរលើកមុននិងណា ថាពូធ្លាប់បានរៀនបញ្ចេកទេសនិងមួយដងនៅលើកដែក អានិងមុនរំដោះ?

ម៉ឺតៈ លើកដែកនិងនៅខាងណាទៅ ។

សុជាៈ លើកដែកនៅខាងទន្លេមេគង្គហ្អ៎?

ម៉ឺតៈ អូ! អានិងកាលដែលរៀន ។

សុជាៈ អានិងមុនរំដោះ?

ម៉ឺតៈ អានិងមុនឆ្នាំ៧៥ ។

សុជាៈ ចុះនៅសាលាព្រែកជ្រៅឬក៏ស្ទឹងជ្រៅ មួយដងមកក្រោយទៀត?

ម៉ឺតៈ ក្រោយនេះហ្អ! ក្រោយ៧៥ ឬក៏មុន៧៥!

សុជាៈ តែខ្ញុំចង់សួរពូបញ្ជាក់វិញណា តើអានិងវានៅស្ទឹងជ្រៅឬក៏នៅព្រែកជ្រៅ?

ម៉ឺតៈ អានេះនៅយើងនេះទេ នៅស្ទឹងជ្រៅយើងតាខ្មៅនេះទេ ។

សុជាៈ អានិងក្រោយឆ្នាំ៧៥ហើយ?

ម៉ឺតៈ អានិង៧៥ហើយ ។

សុជាៈ ចុះរៀននយោបាយ៦ដងនៅកងពល៧០៣អានិងនៅកន្លែងណា?

ម៉ឺតៈ អូ! ភ្លេចច្រើនណាស់ ។

សុជាៈ ៧០៣និងរៀននៅឯណា រៀននៅម្តុំដាំដេងនិងឬក៏នៅឯណា?

ម៉ឺតៈ រៀននិងវាចេះតែរៀនហើយ ជួនកាលបាន១០ថ្ងៃកន្លះខែអីហ្នឹង វារៀនគ្រប់តែកន្លែង ។

សុជាៈ ចុះពេលមកស-២១មានបានរៀនទេ?

ម៉ឺតៈ ស-២១និងគ្រាន់បានតែ រៀនប៉ុនរៀននៅសាលាយើងនៅខាងកើតគុកហ្នឹង ។

សុជាៈ មកខាងណេះជិតផ្សារបឹងកេងកងហ្នឹង?

ម៉ឺតៈ ហ៊ឺ! អានិងនៅជិតលូទឹកស្អុយអាហ្នឹង រៀននៅសាលាហ្នឹង ។

សុជាៈ ឆ្វេងថ្នល់ធំទេ?

ស៊ីវៈ គាត់រៀននៅសាលស៊ីសុវត្ថទេ?

ម៉ឺតៈ រៀននយោបាយនៅសាលស៊ីសុវត្ថនិងមួយដងដែរ ។

**សុជា:** ហើយនៅជិតលូទឹកស្អុយនិងមួយដងទៀត?

**ម៉ើត:** ទៅរៀនមួយដង មួយដងនិងមិនដឹងជាពីណាគេបង្រៀនទេ គេថាខាងលើៗមកមិនដឹងមួយណាទេ ។

**សុជា:** សុន សេន ឬ នួន ជា អីមកទេ?

**ម៉ើត:** គេថាឈ្មោះតាខៀវ ។

**ស៊ីវ:** តាខៀវ ហ្នឹង សុន សេន គាត់ពាក់វែនតា?

**ម៉ើត:** បាទ! ។

**សុជា:** គាត់មកពីខាងក្រសួងការពារជាតិ?

**ម៉ើត:** និងហើយមកបង្រៀននិងនិយាយ បង្រៀនបានតែពីរថ្ងៃហ្នឹង ។

**សុជា:** គាត់និយាយពីស្អីខ្លះ កាលដែលគាត់និយាយ?

**ម៉ើត:** កាលនិងអង្គុយមិនដែលអង្គុយមុខគេអង្គុយតែក្រោយ មិនដឹងជាគេនិយាពីស្អីខ្លះ វាមិនហួសពីការនិយាយពីការចាត់តាំងនិងការបំផុសសតិអារម្មណ៍តែប៉ុណ្ណឹងដដែលៗ មានទាន់មានសិទ្ធចូលបក្សចូលសម្ព័ន្ធគេឯណា អាកន្លែងណាដែលគេថាប្រជុំពីរបីថ្ងៃគេហៅតែអាចក់អាថែមទៅហ្នឹង ដល់គេនិយាយពេញសិទ្ធរបស់គេ គេហៅតែអ្នកធំៗទៅអានិងវាអីចឹង

**ស៊ីវ:** ខាងជើងឈាងខាងកើតរបស់គុកស-២១និងណា វាមានមន្ទីរពេទ្យមួយដែរ?

**ម៉ើត:** កន្លែងនិងមានមន្ទីរពេទ្យមួយ ពេទ្យនិងនៅឈាងខាងជើងជ្រុងទួលស្លែងនិងហ្នង គេហៅថាពេទ្យដីថ្មីអាហ្នឹង អានិងគេហៅសាលារៀនដែរអាហ្នឹង ។

**ស៊ីវ:** ហើយពេទ្យនិងនៅក្នុងក្របខ័ណ្ឌស-២១និងដែរឬក៏ដោយឡែក?

**ម៉ើត:** នៅនិង២១និងដែរ ។

**ស៊ីវ:** អីចឹងមន្ទីរពេទ្យសំរាប់កម្មាភិបាលយុទ្ធជន សំរាប់អ្នកទោសឬក៏រួមគ្នា?

**ម៉ើត:** បើនិយាយទៅមន្ទីរពេទ្យនិងវានៅជាមួយយើងអាដែងមន្ទីរស-២១ហ្នឹង ពេលដែលឈឺអីនិងគេឲ្យទៅដេកនៅនិងទៅ ។

**សុជា:** ចុះបើអ្នកទោស?

**ម៉ើត:** អ្នកទោសគេគ្មានឲ្យដេកនៅកន្លែងនិងទេ គេដឹងតែយកថ្នាំមកចាក់ឬលាបរបួសលាបអីទេណា ។

សុជាៈ តែពេទ្យពីហ្នឹងមកមើលដែរ?

ម៉ើតៈ ពេទ្យនៅក្នុងនិងដែរហ្នឹង ប៉ុនអាពេទ្យក្រៅនិងវាកំរមកណាស់ មានតែពេទ្យប្រចាំការនៅក្នុងហ្នឹង ។

សុជាៈ ពីណាគេជាពេទ្យប្រចាំការនៅក្នុងហ្នឹង?

ម៉ើតៈ ឃើញមានតែពេទ្យទ្រីមួយហ្នឹង ។

សុជាៈ នៅរស់ទេរាល់ថ្ងៃហ្នឹង?

ម៉ើតៈ ហ្អេ!អត់ដឹងទេពេទ្យទ្រីហ្នឹង ព្រោះអីគាត់និងនៅប្រចាំការហ្នឹង គាត់ដើរចល័តតែរហូតហ្នឹង បើតាមមើលវាគ្មានទៅចាក់ថ្នាំអីឯណាទេ វាគ្រាន់តែលាងរបួសហើយនិងសួរចំលើយវៃហ្នឹងប៉ុណ្ណឹង ហើយនិងដើរមើលអ្នកយាមនិងវាដាក់បាយឈឺអីហ្នឹង វាគ្មានថ្នាំអីឯណាដែលប្រកែខ្លាំងអីទេ ។

ស៊ីវៈ បានសេចក្តីថាពេទ្យទ្រីនិងជាអ្នកដើរមើលអ្នកទោសផងមើលយុទ្ធជនផង?

ម៉ើតៈ បាទ!

ស៊ីវៈ តែបើចំពោះកម្មាភិបាលយុទ្ធជនឈឺល្មមៗ គេឲ្យទៅមន្ទីរពេទ្យដែលនៅជាប់សាលារៀននិងហ្អេ?

ម៉ើតៈ បើឈឺល្មមៗគេមិនឲ្យចេញផង ។

សុជាៈ ទាល់តែឈឺធ្ងន់ បើត្រឹមតែផ្តាសសាយផ្តាសអីគេយកថ្នាំទៅអោយ?

ម៉ើតៈ បា!បើកាលណាឈឺធ្ងន់មែនទែន អាធ្ងន់និងមិនស្រួលអត់យកចេញទៀតគេហៅពេទ្យមកមើល ។

ស៊ីវៈ OKខ្ញុំសូមត្រឡប់ទៅចំនុចមួយវិញដើម្បីបញ្ចប់ ខ្ញុំបាននិយាយពីអារឿងដែលតាមសំដីរបស់លោកពូនិងបើខុសហើយគេពិនត្យប្រវត្តិរូបហ្នឹង ហើយឃើញមានបញ្ហាហ្នឹង អាចនិងមានការចោទប្រកាន់ទៅលើអ្នកដែលមានប្រវត្តិរូបមិនល្អនិងណាស់ ប៉ុន្តែវាហាក់ដូចជាមានពីរយ៉ាង គេឃើញយើងធ្វើខុសហើយគេឃើញយើងគេពិនិត្យប្រវត្តិរូបយើង គេធ្វើបក្សដិវត្តន៍យើងនិងណា ទី១គេអាចសន្និដ្ឋានថាយើងខ្មាំង បើយើងខ្មាំងគេអាចយកយើងទៅកម្ទេចអានិងទី១ ទី២គេអាចសន្និដ្ឋានថាយើងគ្រាន់តែជាសមាសភាពមិនសូវល្អទេ គេ

អាចនិងសំរេចថាឲ្យយើងទៅលត់ដំទៅដាំស្រូវនៅព្រៃសហ្នឹង  អានិងគេអាចសំរេចបានទាំងពីរយ៉ាង?

**ម៉ែត:** គេអាចសំរេចបាន  ព្រោះអីទី១គេគ្រាន់តែនិយាយថាដូចពាក្យសំដីយើងមិនល្អ  គឺថាដូចចង់មិនចង់គឺខ្លាំងហើយអាហ្នឹង  យើងចង់ឬមិនចង់ខ្លាំងហើយ  ហើយទី២គឺគេគ្រាន់តែកែលំអរថាបើយើងសំដីអីចឹងហើយ  យើងត្រូវកសាងត្រូវតែពង្រឹងគោលជំហរឡើងវិញ  កុំឲ្យវាទៅតាមមនោសញ្ចេតនារបស់យើងណា  អានិងមានគេណែនាំអីចឹងវិញឯណា  មុននិងមានគុណវិបត្តិហើយក៏មានគុណសម្បត្តិតាមក្រោយវិញដែរអានិងគេតិទានគ្នាតែអីចឹងទេ ។

**ស៊ីវ:** អីចឹងត្រឹមថ្នាក់ណាដែលមានសិទ្ធសំរេចក្នុងបញ្ហាហ្នឹង  ថ្នាក់ណាមានសិទ្ធសំរេចថាតើគេនិងយកយើងទៅសំលាប់  ឬក៏គេនិងយកយើងទៅអប់រំនិងកសាងតែប៉ុណ្ណឹង  ហ៊ុយឬក៏ឌុចខ្លួនឯងឬក៏ថ្នាក់ណាបានសំរេចបាន?

**ម៉ែត:** អានិងបើនិយាយទៅវាមានតែអាឌុចទេដែលអាចសំរេចនោះ  ឌុចនិងហួរនិងពីរនាក់និងគេច្រើនតែពិភាក្សាគ្នាគេច្រើនលេងផ្លូវកាត់  អាណាល្មមៗគេខ្ជិលឲ្យទៅថ្នាក់លើដឹងណាអីចឹងច្រើនតែលេងផ្លូវកាត់របស់គេ ។

**សុជា:** ចុះបើអ្នកដែលត្រូវគេយកទៅសម្លាប់និងជាអ្នកធំដែរ  បើតាមខ្ញុំដឹងដូចថាទាល់តែមាន  នៅក្នុងអង្គភាពជាមួយគ្នា ។

**ស៊ីវ:** ទេឲ្យខ្ញុំនិយាយតែក្នុងអង្គភាពស-២១ហ្នឹង  មិនមែននិយាយខាងក្រៅទេគេប្រជុំអ្នកយាមកងការពារអីទេ ។

**ម៉ែត:** ដួនកាលហួរនិងឌុចអីនិងក៏ទៅជាមួយដែរហ្នឹង  មិនមែនតែគេមិនទៅទេ  ពេលនិងគេត្រូវទៅជាមួយដែរ ។

**សុជា:** គេទៅណា?

**ម៉ែត:** ទៅអាកន្លែងសម្លាប់មនុស្សនិងណា ។

**សុជា:** ទៅអាកន្លែងសម្លាប់នៅជើងឯកនិងហ្អេ?

**ម៉ែត:** កន្លែងបឹងជើងឯកក៏ទៅអាកន្លែងនៅក្បែរៗនិងក៏ទៅដែរ  ព្រោះអីគេមិនបណ្តែតបណ្តោយឲ្យយើងទៅតែឯងៗទេ  អានិងសុទ្ធតែគេទៅខ្លួនគេដែរទេ  ប៉ុនគេត្រូវធ្វើគេធ្វើបើគេមិនត្រូវធ្វើគេក្រពាត់ដៃមើលអានិងវាអីចឹងទេ ។

**ស៊ីវៈ** អាកន្លែងជិតៗនិងមានប៉ុន្មានកន្លែងដែលគេប្រើដើម្បីសម្លាប់មនុស្ស?

**ម៉េតៈ** វាពិបាករាប់កន្លែងណាស់ព្រោះកន្លែងដែលនៅជិតនិងវាមិនសូវជាមានច្រើនទេ វាច្រើនដូចថាអ្នកធំអ្នកអីអីចឹងគេខ្ចិលយកទៅឆ្ងាយអីចឹងទៅណា ។

**សុជាៈ** ខ្ញុំសូមអរគុណពូច្រើនដែលបានឲ្យសួរមួយសារទៀត ហើយបានសួរពូនៅសំនួរច្រើនដែរមិញហ្នឹង

# ចប់